**សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Scienes Economiques

*Royal University of Law and Economics*

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិស្ត្រីក្នុងវិស័យអប់រំនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ក. **គឹម សុភ័ក្រ**

ក. **សេង ច័ន្ទទេវី**

សាស្ត្រាចារ្យណែនាំ

លោក **ជុំ ចាន់វិត្ថា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៤

ឆ្នាំចូលរៀន ២០១១

ឆ្នាំសរសេរសារណា ២០១៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **គីម សុភ័ក្រ** និង **សេង ច័ន្ទទេវី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្ត ជំនាន់ទី១៤ ក្រុមL4A4 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច នៅក្នុងឆ្នាំសិក្សា២០១៣-២០១៤។

## សូមធ្វើការវេកិច្ច និង កតញ្ញូតាធម៌ចំពោះ

- លោកឪពុក អ្នកម្តាយដែលមានគុណយ៉ាងធំធេង មិនអាចកាត់ថ្លៃបានចំពោះរូបកូនដោយបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សារូបកូន និងបានបញ្ជូនកូនឲ្យទៅសាលារៀនដើម្បីសិក្សារៀនសូត្រក្រេបជញ្ជក់យកចំណេះដឹង ដើម្បីរស់នៅប្រកបដោយកិត្តិយស និងសេចក្តីថ្លៃថ្នូរ។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី សាស្រ្តាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់។

ជាពិសេសលោកសាស្រ្តាចារ្យ **ជុំ ចាន់វិត្ថា** សាស្រ្តាចារ្យមុខវិជ្ជា**នីតិអន្តរជាតិសាធារណៈ** ដែលបានណែនាំយើងខ្ញុំនៅក្នុងការស្រាវជ្រាវឯកសារ បង្ហាញទិសដៅ និងផ្តល់ជាអនុសាសន៍ល្អៗ សម្រាប់ការតាក់តែងនូវកិច្ចការស្រាវជ្រាវរហូតដល់បានបញ្ចប់ដោយជោគជ័យ។

គុណូបការៈដ៏ថ្លៃថ្លាទាំងនេះ ធ្វើឲ្យយើងខ្ញុំដឹងគុណ និងចងចាំជានិច្ចមិនអាចបំភ្លេចបាន និងសូមប្រសិទ្ធពរជ័យ សូមលោកអ្នកទាំងអស់បានជួបប្រទះតែគុណបុណ្យព្រះរតនត្រ័យ ដែលជាវត្ថុស័ក្តសិទ្ធិក្នុងលោកមានពុទ្ធរតនៈ ធម្មរតនៈ និងសង្ឃរតនៈ ជាទីពឹងគ្រប់ពេលវេលា ព្រមទាំងពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតអំពីយើងខ្ញុំ។

# **អារម្ភកថា**

កម្រងសារណាស្តីអំពី **សិទ្ធិស្ត្រីក្នុងវិស័យអប់រំនៅកម្ពុជា** គឺជាប្រធានបទមួយដែលយើងខ្ញុំបានខិតខំប្រឹងប្រែងព្យាយាមស្រាវជ្រាវតាមរយៈមធ្យោបាយផ្សេងៗ ដើម្បីចងក្រងឡើងក្រោយពីបញ្ចប់ការសិក្សាផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ចំណេះដឹងទាំងឡាយដែលយើងខ្ញុំបានទទួលពី លោកសាស្ត្រាចារ្យរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងរយៈពេល ៤ ឆ្នាំនៃការសិក្សាកន្លងមករួមទាំងការសិក្សាស្រាវជ្រាវឯកសារទាំងឡាយដោយខ្លួនឯងរួមផ្សំ និងការជួយណែនាំយ៉ាងអស់ពីកម្លាំងកាយចិត្តរបស់លោកសាស្ត្រាចារ្យ **ជុំ ចាន់វិឆ្លា** ព្រមទាំងឯកសារផ្សេងៗរបស់ក្រសួងកិច្ចការនារី និងសៀវភៅមួយចំនួនដែលបានដាក់ឲ្យប្រើប្រាស់នៅក្នុងគេហទំព័រក្រសួងអប់រំ យុវជន និងកីឡា ដែលអាចធ្វើឲ្យកិច្ចការចងក្រងកម្រងសារណារបស់យើងខ្ញុំអាចមានផលជាវិជ្ជមាន។

យើងខ្ញុំសង្ឃឹមថាការចងក្រងរៀបរៀងសារណានេះ អាចជាប្រយោជន៍និងអាចផ្តល់នូវគំនិតល្អៗមួយចំនួន ក៏ដូចជាជួយសម្រួលដល់ការសិក្សាស្រាវជ្រាវទាក់ទងលើបញ្ហា **សិទ្ធិស្ត្រីក្នុងវិស័យអប់រំនៅកម្ពុជា** ទៅដល់សិស្ស និស្សិតបានមួយកម្រិតទៀត។

ជាចុងបញ្ចប់នេះយើងខ្ញុំទាំងពីរនាក់ នឹងរងចាំទទួលនូវការរិះគន់ក្នុងន័យស្ថាបនានិងសុំអភ័យទោសចំពោះកំហុសឆ្គងទាំងឡាយដែលកើតមានក្នុងការចងក្រងសារណានេះឡើង។

យើងខ្ញុំសូមអរគុណទុកជាមុន សម្រាប់ការកែលម្អរបស់លោក លោកស្រី និងមិត្តអ្នកអានទាំងអស់ដោយសេចក្តីរីករាយ។

# មាតិកា


សេចក្តីផ្តើម ........................................................................................ ១

ជំពូកទី១ ៖ ការទទួលបានសិទ្ធិក្នុងវិស័យអប់រំ

ផ្នែកទី១ ៖ ការទទួលបានសិទ្ធិតាមរយៈរដ្ឋាភិបាល ........................................................ ៣

១.១ សិទ្ធិទទួលបានតាមឯកសារគតិយុត្ត ........................................................ ៣

១.១.១ សិទ្ធិទទួលបាននៅក្នុងសម័យបុរាណ ........................................................ ៤

១.១.២ សិទ្ធិទទួលបានការអប់រំនៅសម័យទំនើប ........................................................ ៤

១.១.៣ សិទ្ធិទទួលបានការអប់រំនៅសម័យព្រះរាជាណាចក្រទី២ ឆ្នាំ ១៩៩៣ .................. ៧

១.២ ការទទួលបានសិទ្ធិតាមរយៈយុទ្ធសាស្រ្តរបស់រដ្ឋាភិបាល ........................................ ៩

១.២.១ គោលនយោបាយយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី១ ................................ ៩

១.២.២ គោលនយោបាយយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី២ ................................ ១០

១.២.៣ គោលនយោបាយយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ ................................ ១៣

១.៣ ផែនការនៃការអនុវត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា ................................ ..១៥

១.៣.១ ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០០៩-២០១៣ ........................................ ..១៥

១.៣.២ ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៤-២០១៨ ........................................ .២០

១.៣.៣ គោលការណ៍របស់ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៤-២០១៨ .............. .២១

ផ្នែកទី២ ការទទួលបានតាមរយៈអង្គការក្រៅរដ្ឋាភិបាល ........................................ ២២

២.១ ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ........................................ ២២

២.១.១ ទំនាក់ទំនងជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា ................................ ២៣

២.១.២ របាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាល ........................................ .២៤

២.១.៣ ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលទៅលើការអប់រំសម្រាប់ទាំងអស់គ្នា...២៤

២.២អង្គការអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ........................................ .២៤

ជំពូកទី២ ៖ ស្ថានភាពក្នុងការអនុវត្តសិទ្ធិស្រ្តីក្នុងវិស័យអប់រំ រវាងប៉ុន្មានឆ្នាំចុងក្រោយ ........................................ ២៦

ផ្នែកទី១ ៖ គោលដៅក្នុងការបណ្តុះបណ្តាល ........................................ .២៦

១.១ ទីក្រុង ........................................................................................................ ២៧

១.១.១ ការអប់រំនៅក្នុងគ្រឹះស្ថានសាធារណៈ ................................................................ ២៧

ក.ថ្នាក់មត្តេយ្យសិក្សា ........................................................................................ ២៨

ខ.ថ្នាក់បឋមសិក្សា ............................................................................................ ៣០

គ.ថ្នាក់មធ្យមសិក្សា .......................................................................................... ៣៣

ឃ.ថ្នាក់មធ្យមសិក្សាទុតិយភូមិ .......................................................................... ៣៤

ង.ថ្នាក់ឧត្តមសិក្សា .......................................................................................... ៣៥

១.១.២ ការអប់រំនៅក្នុងគ្រឹះស្ថានឯកជន ...................................................................... ៣៦

១.២ តាមបណ្តាលខេត្តមួយចំនួន ............................................................................... ៣៦

១.២.១ ទីរួមខេត្ត ................................................................................................ ៣៨

១.២.២ ទីជាច់ស្រយាល ........................................................................................ ៣៩

ផ្នែកទី ២៖ ការអភិវឌ្ឍន៍ និងឧបសគ្គនាពេលបច្ចុប្បន្ន ............................................... ៤០

១.១ ការអភិវឌ្ឍន៍ .................................................................................................. ៤១

១.១.១ បរិបទគោលនយោបាយ ............................................................................ ៤៣

១.១.២ ការផ្តល់អាហារូបករណ៍ .......................................................................... ៤៣

១.២ ឧបសគ្គនាពេលបច្ចុប្បន្ន ..................................................................................... ៤៤

១.២.១ កត្តាក្រៅប្រព័ន្ធអប់រំ ............................................................................... ៤៥

១.២.២ បញ្ហានៅកម្រិតសាលា ........................................................................... ៤៥

១.២.៣ បញ្ហាទាក់ទងនឹងគោលនយោបាយតាមវិស័យ និងសមត្ថភាពស្ថាប័ន ............ ៤៦

សេចក្តីសន្និដ្ឋាន .................................................................................................. ៤៧

អនុសាសន៍ ......................................................................................................... ៤៩

ឧបសម្ព័ន្ធ

ឯកសារយោង

# សេចក្តីផ្តើម

បញ្ហាសិក្សាអប់រំ គឺជាបញ្ហាមួយដែលគួរលើកយកមកពិចារណាព្រោះបញ្ហានេះជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការរីកចម្រើននៃប្រទេសជាតិនាសម័យបច្ចេកវិទ្យាយើងនេះ។

ជាពិសេសជាងនេះទៅទៀត គឺប្រទេសកម្ពុជាយើងតែម្តង ដោយសារតែប្រទេសយើងជាប្រទេសមួយដែលមានកេរ្តិ៍ដំណែល ទំនៀមទម្លាប់ ប្រពៃណីយ៉ាងតឹងរឹងចំពោះកូនស្រី ហើយដែលមនុស្សជំនាន់ដើមនៃយើងលោកបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហាកូនស្រីរបស់លោក។

លោកតែងតែចាត់ទុកថា ផ្ទះណាដែលមានកូនស្រីប្រៀបដូចជាមានប្រហុកមួយក្រឡនៅក្នុង ផ្ទះអញ្ចឹងដែរ បើសិនជាលោកមិនបានយកចិត្តទុកដាក់ ថែរក្សាប្រហុកនោះឲ្យបានជិតដល់ទេ ប្រាកដ ជាមានក្លិនមិនល្អជះចេញមកខាងក្រៅផ្ទះ ដែលធ្វើឲ្យញាតិជិតខាងមានការនិយាយនិន្ទាមិនល្អជាក់ ជាមិនខានឡើយ។ ហេតុដូច្នេះហើយ បានជាលោកតែងតែមានការរារាំងឃាំងឃាត់កូនស្រីមិនឲ្យ ទៅសាលារៀនដោយទុកឲ្យធ្វើការងារក្នុងផ្ទះតែប៉ុណ្ណោះ។ លោកតែងមានទស្សនៈថាកូនស្រីបង្វិល ចង្ក្រានមិនជុំ និងបន្ទាប់ពីរៀបការរួចហើយ កូនស្រីត្រូវនៅផ្ទះមើលរៀបចំទុកដាក់កូនចៅ ផ្ទះសម្បែង ឯបុរសជាស្វាមីទើបត្រូវចេញទៅធ្វើការរកស៊ីនៅខាងក្រៅផ្ទះ។ បែបនេះហើយបានជាលោកតែងផ្តល់ អត្ថិភាពឲ្យទៅកូនប្រុសបានទៅរៀននៅសាលាជាជាងកូនស្រី។

សម័យក្រោយមកទៀត ដោយសារតែភាពរីកចម្រើននៃពិភពលោក រាជរដ្ឋាភិបាលបានរៀបចំ រចនាសម្ព័ន្ធថ្មីដោយធ្វើការគិតពិចារណាទៅលើវិស័យអប់រំ ដែលមានសមភាពរវាងបុរសនិងស្ត្រី មានច្បាប់មួយចំនួនដែលបានធ្វើការចែងពាក់ព័ន្ធទៅនឹងការផ្តល់ឲ្យស្ត្រីនៅសិទ្ធក្នុងវិស័យអប់រំ។ ក្នុងនោះមានដូចជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារក្នុងនោះ ផងដែរនាថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញា អន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលតម្រូវឲ្យរាជរដ្ឋាភិ-បាលកម្ពុជាមានកាតព្វកិច្ចយករាល់បទប្បញ្ញត្តិទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ មកអនុវត្តព្រមទាំងធ្វើសេចក្តីរាយការណ៍ ស្តីពីការអនុវត្តជូនអគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ វិញ ក្រៅពីនោះផងដែរ ក៏នៅមានច្បាប់មួយចំនួនទៀតដែលបានចែងដោយផ្តល់អត្ថិភាពឲ្យស្ត្រីបាន ចូលរៀនដូចជាបុរសដែរ។

នៅក្នុងកិច្ចការសារណានេះ យើងខ្ញុំបានបែងចែកវាចេញជាពីរជំពូកធំៗ ដែលក្នុងមួយជំពូក យើងបានចែកទៅជាពីរផ្នែកធំៗ ហើយនៅក្នុងផ្នែកនីមួយៗ មានចែកចេញជាចំណុចតូចៗ ពី

លើនោះបន្ថែមទៀត។ ក្នុងជំពូកទី១ ក្រុមរបស់យើងខ្ញុំនឹងធ្វើការរៀបរាប់ទាក់ទងទៅនឹងប្រវត្តិរបស់ស្ត្រីក្នុង ***ការទទួលបានសិទ្ធិក្នុងវិស័យអប់រំ*** ហើយនិងជំពូកទី២ យើងនឹងធ្វើការបកស្រាយទៅលើ ***ស្ថានភាពក្នុងការអនុវត្តសិទ្ធិស្ត្រីក្នុងវិស័យអប់រំក្នុងកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។***

ដើម្បីឲ្យកាន់តែជ្រៀបច្បាស់ទៀត សូមពិនិត្យទៅលើកិច្ចការរបស់យើងខ្ញុំនៅទំព័រខាងក្រោម ដែលនឹងរៀបរាប់លម្អិតនៅក្នុងជំពូកទាំងពីរជាបន្តបន្ទាប់។

# សិទ្ធិស្រ្តីក្នុងវិស័យអប់រំនៅកម្ពុជា

## ជំពូកទី១ ៖ ការទទួលបានសិទ្ធិក្នុងវិស័យអប់រំ

ការសិក្សាអប់រំ គឺជាវិស័យមួយដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍សមត្ថភាពរបស់មនុស្សគ្រប់រូបនៅលើសកលលោកយើងនេះ។ ព្រះរាជាណាចក្រកម្ពុជា យើងក៏បានចាត់ទុកវិស័យអប់រំគឺជាកត្តាចំបងក្នុងការអភិវឌ្ឍន៍សមត្ថភាពរបស់មនុស្សគ្រប់រូប ជាពិសេសនោះគឺស្រ្តី និង កុមារី ព្រោះមានតែការអប់រំទេ ដែលអាចឲ្យស្រ្តី និងកុមារី ជៀសផុតពីភាពអវិជ្ជា ធ្វើឲ្យខ្លួនមានភាព ក្លាហាន មោះមុត ជឿជាក់ លើសមត្ថភាពខ្លួនឯង គ្រប់កំរិត គ្រប់វិស័យ និងគ្រប់ផ្នែក។ ជាងនេះទៅទៀតគេយល់ថា ស្រ្តីក៏ជាកំលាំងមួយដ៏ខ្លាំងក្លាក្នុងការជួយឲ្យសង្គមជាតិរីកចម្រើនផងដែរ។

### ផ្នែកទី១ ៖ ការទទួលបានសិទ្ធិតាមរយៈរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលកម្ពុជា គឺដើរតួនាទីសំខាន់ណាស់ ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានភាពរីកចម្រើន។ ដោយប្រទះឃើញថា សង្គមជួបប្រទះបញ្ហាមួយចំនួនដូចជា បញ្ហាដែលកើតឡើងចំពោះស្រ្តីគឺនៅតែមាន ជាពិសេសគឺបញ្ហាក្នុងវិស័យអប់រំ ដែលស្រ្តីមួយចំនួនធំពុំទទួលបានការអប់រំ ក៏ដូចជាសមភាពរវាងបុរស និងស្រ្តីគឺនៅមានគម្លាតឆ្ងាយ ដូច្នេះរាជរដ្ឋាភិបាលក៏បានខិតខំប្រឹងប្រែងលុបបំបាត់បញ្ហាទាំងនេះ ដោយផ្តល់សិទ្ធិដល់ស្រ្តីតាមរយៈយុទ្ធសាស្រ្តជាច្រើនរបស់រាជរដ្ឋាភិបាល។

#### ១.១ សិទ្ធិទទួលបានតាមរយៈឯកសារគតិយុត្តនានា

ដើម្បីឆ្លើយតបទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធានាថាប្រជាពលរដ្ឋគ្រប់រូបទទួលបាននូវ ការអប់រំមូលដ្ឋាន រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការបង្កើតឲ្យមាននូវ ផែនការជាតិអប់រំ សម្រាប់ទាំងអស់គ្នា ក្នុងនោះផងដែររាជរដ្ឋាភិបាលក៏បានរៀបចំផងដែរនូវគោលនយោបាយជាច្រើន ដើម្បីឲ្យផែនការជាតិនេះបានជោគជ័យ។ ទទឹមនឹងនេះផងដែរ ដើម្បីឲ្យស្រ្តីទទួលបាននូវសិទ្ធិពេញលេញដូចបុរស ជាពិសេសក្នុងវិស័យអប់រំព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ និងផ្តល់នូវសច្ចាប័នលើលិខិតុបករណ៍អន្តរជាតិនានា ដូចជា: សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អនុសញ្ញាស្តីពីការបំបាត់ចោលសព្វ បែបយ៉ាងនៃការប្រកាន់ពូជសាសន៍ អនុសញ្ញាស្តីពីសិទ្ធិកុមារជាដើម ។

### ១.១.១ សិទ្ធិទទួលបាននៅក្នុងសម័យបុរាណ

ប្រទេសកម្ពុជានាសម័យដើម ពុំមែនជាសង្គមដែលគ្រប់ការងារ ឬអំណាចផ្សេងៗ មានបុរសជាអ្នកតំណាងឡើយ។ ពីព្រោះគេសង្កេតឃើញថា ពង្សសាវតាដែលបានឆ្លាក់នៅឯប្រាសាទអង្គដ៏ល្បីល្បាញបានពិពណ៌នាថា ស្ត្រីមានតួនាទីក្នុងការងារ។ ជាពិសេសប្រាសាទអង្គរវត្តនៅសតវត្សទី ១៣ បានឃើញថាស្ត្រីបានធ្វើការងារ ជាតារាវិទូ និងជាហោរា ចៅក្រម និងជាឆ្មាំយាមវាំង។ [1](ហើយជនជាតិចិននោះបានបញ្ជាក់បន្ថែមទៀតថា ស្ត្រីមានជំនាញខាងធ្វើពាណិជ្ជកម្មមានសេរី ភាព និងអាចធ្វើដំណើរទៅទីឆ្ងាយៗតាំងពីនៅក្មេងមកម្លេះ និងមានបុព្វសិទ្ធិក្នុងការស្លៀកពាក់ដែល បុព្វសិទ្ធិនេះពុំមានចំពោះបុរសឡើយ។ នេះសបញ្ជាក់ឲ្យឃើញថា សិទ្ធិនៃការទទួលបានការអប់រំ របស់ស្ត្រីគឺមានតម្លៃយ៉ាងពេញលេញ។

### ១.១.២ សិទ្ធិទទួលបានការអប់រំនៅសម័យទំនើប

ចាប់តាំងពីកម្ពុជាទទួលបានឯករាជ្យមក សាលាទំនើបមានការរីកចម្រើនឡើង គួរឲ្យកត់សម្គាល់ កូនខ្មែរមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះ ការរៀនសូត្រធ្វើឲ្យវប្បធម៌ អរិយធម៌ ក៏ចាប់ មានពន្លឺរស្មីឡើងវិញដែរ។ សាលារៀនក៏បានកើនឡើងជារៀងរាល់ឆ្នាំ ហើយមាននៅស្ទើរតែគ្រប់ទិសទី។ សូម្បីតែនៅតាមភូមិដាច់ស្រយាលខ្លះក៏ដោយ ក៏គេប្រទះឃើញមានសាលាបឋមសិក្សាដែរ។ ចំណែកឯអនុវិទ្យាល័យ ឬវិទ្យាល័យក្រៅពីនៅក្នុងទីក្រុង ត្រូវបានសង់ឡើងដាច់ចេញពីកម្មសិទ្ធដី វត្តតែម្តង គឺនៅតាមទីរួមខេត្ត ឬក្រុងធំដែរ។ ប៉ុន្តែសាលាខ្លះទៀត ដូចជាសាលាវត្តថ្មីនៅតែបន្តការរៀនសូត្រនៅក្នុងបរិវេណវត្ត មិនទាន់បានផ្តាច់ទំនាក់ទំនងពីវត្តបាន សាលាបឋមសិក្សាភាគច្រើន នៅតែស្ថិតនៅក្នុងបរិវេណវត្ត ហើយព្រះសង្ឃនៅតែរក្សាទំនាក់ទំនងល្អជួយសាងសង់សាលារៀន ឧបត្ថម្ភ តុ កៅអី និងសម្ភារៈសិក្សាជាច្រើនទៀត។

ក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលបានខិតខំយកចិត្តទុកដាក់អស់ពីសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់កូនខ្មែរ។ រាជរដ្ឋាភិបាលខ្មែរបានចំណាយថវិកាយ៉ាងច្រើនលើសលប់នៅក្នុងឆ្នាំ ១៩៦៧ សម្រាប់វិស័យអប់រំ។ ប៉ុន្តែទោះបីរាជរដ្ឋាភិបាល និងប្រជារាស្ត្រខិតខំបែបនេះក៏ដោយ ក៏នៅតែពុំអាចឆ្លើយតបនឹងការ ស្រេកឃ្លានចំណេះដឹងរបស់កុលបុត្រខ្មែរបាននៅឡើយ ពីព្រោះថាសាលារដ្ឋ ទាំងបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សាពុំមានលទ្ធភាពទទួលកូនខ្មែរដែលចង់រៀនសូត្របានទាំងអស់គ្នាទេ អ្វី ដែលសំខាន់នោះ គឺថាប្រព័ន្ធអប់រំថ្មីបានធ្វើឲ្យក្មេងស្រីអាចបានចូលរៀនសូត្រដូចក្មេងប្រុសដែរ។ ត្បិតអីពីមុនក្មេងស្រីកម្របានរៀនអក្សរណាស់ មានខ្លះ

[1] ការប្រើប្រាស់ដៃទាំងគូ ស្ត្រីក្នុងវិស័យអប់រំនៅកម្ពុជា

ដែរនៅ ឆ្នាំ១៨៧៣[2] គេសង្កេតឃើញនៅតាម សាលាបារាំងបង្កើតឃុំ ឬខ័ណ្ឌមានក្មេងស្រីចូលរៀន មួយចំនួនតូច ប៉ុន្តែការសិក្សារបស់ក្មេងស្រីនៅ ពេលនោះពុំទាន់មានលក្ខណៈជាប់លាប់នៅឡើយទេ។

ក្នុងឆ្នាំ ១៩១១ នៅភ្នំពេញបានបង្កើតសាលារៀនសម្រាប់ក្មេងស្រី គឺសាលានរោត្តម ទន្ទឹម នឹងនោះបង្កើតសាលាឯកជនពីរទៀតសម្រាប់នារីនៅឆ្នាំ ១៩១១ គឺសាលាមាលីការ និងសុធារស (កសាងឡើងដោយព្រះអង្គម្ចាស់ម៉ាលីកា និងសុធារស) នៅក្រោយវត្តបុទុមវតី សម្រាប់កូនឧកញ៉ា មន្ត្រី និងកូនស្តេចតែប៉ុណ្ណោះ ។

នៅក្នុងឆ្នាំ ១៩១៩ បានបង្កើតសាលាសម្រាប់នារីមួយទៀតនៅតាមផ្លូវប៉ូលប៊ែរ ឈ្មោះថា សាលាឌូដាដឺឡាប្រេ្ហ ជាសាលាបារាំង មានទីតាំងដើមទីកន្លែងវាលមេរុ ក្រោយមកផ្លាស់ទីតាំង ទៅនៅត្រង់សាលាចតុមុខសព្វថ្ងៃ បន្ទាប់មកផ្លាស់ទៅនៅត្រង់វិទ្យាស្ថានគរុកោសល្យជាន់ខ្ពស់ បច្ចុប្បន្ន ចុងក្រោយផ្លាស់ទៅត្រង់កន្លែងសាលាវត្តកោះសព្វថ្ងៃ ហើយក៏បាត់បង់ឈ្មោះសាលានេះ តែម្តង។ ចំពោះនៅតាមខេត្ត យើងសង្កេតឃើមានកសាងសាលាសម្រាប់ក្មេងស្រីតិចតួចណាស់។

ប្រហែលជាក្នុងសម័យក្រោយឯករាជ្យ ឬក៏ក្នុងឆ្នាំ ១៩៧០-១៩៧៥ សាលាសម្រាប់ក្មេងស្រី មានការវិវត្តន៍ រីកចម្រើននៅតាមខេត្តនានាដូចជា ៖ ខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ចាម កំពង់ស្ពឺ កំពង់ធំ សៀមរាប ព្រៃវែង ស្វាយរៀង និងតាកែវ ។

**ស្ថិតិសាលា និងសិស្សស្រី**[3]

| មណ្ឌល | សាលា | សិស្សស្រី |
|---|---|---|
| ភ្នំពេញ | ៣ | ២៩០ |
| បាត់ដំបង | ១ | ៦០ |
| ខេត្តកណ្តាល | ១ | ៥១ |
| កំពង់ចាម | ១ | ២១ |
| កំពង់ស្ពឺ | ១ | ២៦ |
| ព្រៃវែង | ១ | ៤៩ |
| កំបង់ធំ | ១ | ៣០ |
| ពោធិ៍សាត់ | ១ | ៤២ |
| សៀបរាប | ១ | ៣៧ |

[2] Ministère de l'information du government royal Cambodge "l'Enseignement"Phnom Penh 1962 p 121

[3] René Morizon "Enseignement des filles"Monographie du Cambodge .Pans . 1931. p 185

| | | |
|---|---|---|
| ស្វាយរៀង | ១ | ១៦ |
| តាកែវ | ១ | ៤៦ |
| សរុប | ១៣ | ៦៦៧ |

ដោយមានការវិវត្តន៍នៃប្រព័ន្ធអប់រំ នៅសាលាវត្តមកជាសាលាទំនើបនោះ យើងឃើញមានការកសាងសាលារៀនច្រើន និងមានសិស្សចូលរៀនទាំងស្រី ទាំងប្រុស គិតតាំងពីការបែងចែកពីសាលាកុដិ ។

ដោយឡែកលុះមកដល់ ឆ្នាំ ១៩៧៥-១៩៧៩ ជាដំណាក់កាលមួយដ៏គួរឲ្យឈឺចាប់ខ្លោចផ្សាបំផុតដោយសារតែសមិទ្ធិផលដែលទទួលបានក្នុងវិស័យអប់រំ ចាប់ពីទសវត្សទី៥០ មកដល់ទសវត្សទី៧០ ត្រូវបានលុបបំបាត់ចោលអស់រលីងនៅក្នុងរបបខ្មែរក្រហម ។

សាលារៀនទាំងអស់ត្រូវបានបិទទ្វារ ហើយបុគ្គលលិកសិក្សាត្រូវបានកាប់សម្លាប់ ព្រោះតែអ្នកសិក្សាទាំងអស់គឺជាសត្រូវនៃរបបនេះ។ ការអប់រំនៅក្នុងសម័យនោះ គឺបណ្តុះបណ្តាលឲ្យកុមារក្លាយជាមនុស្សកំណាចឃោឃៅហ៊ានកាប់សម្លាប់មនុស្សដូចគ្នា មិនលើកលែងសូម្បីតែឪពុកម្តាយបងប្អូន ឬញាតិជិតខាងក៏ដោយ។ អស់រយៈពេលជិតបួនឆ្នាំដែលគ្រប់គ្រងដោយរបបនេះ បានធ្វើឲ្យប្រជាពលរដ្ឋយើងជួបប្រទះតែនឹងការអត់ឃ្លាន កូនមិនស្គាល់ឪពុក ប្រពន្ធមិនស្គាល់ប្តី ជីវិតរស់នៅដោយក្តីភ័យខ្លាច គ្មានការជឿទុកចិត្តលើខ្លួនឯង ។

ដោយសារតែប្រព័ន្ធអប់រំមិនមានដំណើរការនៅក្នុងរបបនេះ ជាហេតុធ្វើឲ្យប្រទេសយើងជួបការលំបាកក្នុងវិស័យអប់រំ គឺយើងត្រូវចាប់ផ្តើមសារជាថ្មីឡើងវិញទាំងអស់ ដូចដែលការចាប់ផ្តើមពី ជំនាន់ទសវត្សទី៥០ ដែរ។

ដល់ឆ្នាំ១៩៧៩-១៩៩៣ គឺជាដំណាក់កាលដែលប្រជាពលខ្មែរទាំងអស់ងើបឡើងពីរណ្តៅអនន្តរកម្មក្នុងរបបដ៏សែនឃោឃៅ មកស្ថិតនៅក្រោមការកសាងឡើងវិញអស់មួយរយៈកន្លងមក។ គេសង្កេតឃើញថា ប្រទេសកម្ពុជាហាក់ដូចជាមានការវិវត្តន៍ក្នុងវិស័យអប់រំជាបណ្តើរៗ ប៉ុន្តែបញ្ហាកុមារីចំពោះវិស័យអប់រំនៅតែមានបន្តដដែល ដោយសារគំនិតមាតា-បិតាមួយចំនួននៅមាននិន្នាកាមិនចង់ឲ្យកូនស្រីទៅរៀនទេ កូនស្រីត្រូវនៅថែរក្សាផ្ទះសម្បែង មើលថែទាំងប្អូនដែលនៅតូចៗ និងជួយការងារម្តាយខ្លះៗ ។

ទោះបីកុមារីបានចូលរៀនហើយក៏ដោយ ក៏ការសិក្សារបស់គេពុំបានបិតស្ថេរយូរអង្វែងឲ្យបានចប់ចុងចប់ដើមដែរ ដោយសារតែពេលដែលនាងមានវ័យធំបន្តិចឪពុក-ម្តាយតម្រូវឲ្យនាងមាន

គ្រួសារ ឬឲ្យនាងប្រកបរបរអាជីវកម្មតូចៗ ទៅតាមលទ្ធភាពដែលគាត់មាន។ បើនៅទីប្រជុំជន កុមារីអាចមានលទ្ធភាពរៀនបានច្រើនជាងកុមារីដែលនៅតាមជនបទព្រោះថាៈ

- នៅទីប្រជុំជន : ឪពុក-ម្តាយច្រើនមានលទ្ធភាពឲ្យកូនស្រី អាចទៅរៀនបានច្រើនជាងជនបទ ដោយមានសាលារៀននៅជិតផ្ទះ ជីវភាពអំណោយផលងាយស្រួលឲ្យឪពុក-ម្តាយ យល់ពីការអប់រំដល់កូនស្រី និងផលវិបាកនៃការមិនចេះអក្សរ។
- នៅតាមជនបទ : លទ្ធភាពដែលអាចឲ្យកូនស្រីទៅរៀនមានតិចតួច ជួនកាលអាចគ្មានសាលារៀននៅជិតផ្ទះពិបាកក្នុងការធ្វើដំណើរទៅសិក្សា បើសិនមានបញ្ហារឿងជីវភាព ឬត្រូវការមនុស្សឲ្យជួយកិច្ចការផ្ទះ គេនឹងជ្រើសរើសកូនស្រីមុនកូនប្រុសមិនខាន។

  ភាគច្រើននៃឪពុក-ម្តាយតែងតែយល់ថា កូនស្រីរៀនច្រើនក៏មិនបានការដែរ ទំនេរនៅធ្វើការ ផ្ទះល្អជាង។

### ១.១.៣ សិទ្ធិទទួលបានការអប់រំ នៅសម័យព្រះរាជាណាចក្រកម្ពុជាទី២ ឆ្នាំ ១៩៩៣

ក្រោយពីទទួលបានកិច្ចព្រមព្រៀងនៅទីក្រុងបារីសថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ មកកម្ពុជាបានឈានដល់ការបោះឆ្នោតមួយជាសកលនៅក្នុងឆ្នាំ១៩៩៣ ដើម្បីជើសរើសតំណាងរាស្ត្រសម្រាប់ខេត្តនីមួយៗ ប្រចាំព្រះរាជាណាចក្រកម្ពុជា។ អ្នកតំណាងរាស្ត្របានធ្វើការយ៉ាងមមាញឹកក្នុងការអនុម័តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។ ហើយនៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនេះផងដែរ ក៏បានលើកកម្ពស់វិស័យអប់រំដែលក្នុងរដ្ឋធម្មនុញ្ញបានចែងដូចតទៅ:

- "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិទទួលបានការគាំពារក្នុងស្ថានភាពមានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ ។"

  "រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឲ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឲ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។[4]"
- "មាតា-បិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ។ កូនមានករណីកិច្ចចញ្ចឹម និងបីបាច់ថែរក្សាមាតា-បិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ ។[5]"

[4]មាត្រ៤៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[5]មាត្រ៤៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

- "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គ ការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំង អនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងកុមារ ។[6]"
- "រដ្ឋត្រូវការពារ និងលើស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឲ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។"

  "រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និងកីឡាដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។[7]"
- "រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឲ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នាក្នុងការកសាងជីវិត ។[8]"
- "រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស។ រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និងថ្នាក់សិក្សាសាធារណៈ និងឯកជននៅគ្រប់ភូមិសិក្សា ។[9]"
- "រដ្ឋផ្តល់កិច្ចការអប់រំថ្នែកបឋម និងមធ្យមសិក្សានៅសាលារៀន សាធារណៈសម្រាប់ប្រជា-ពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិច០៩ ឆ្នាំ ។[10]"
- "រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងមាតា។ រដ្ឋរៀបចំឲ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុកហើយឥតទីពឹង ។[11]"

### ១.២ ការទទួលបានសិទ្ធិតាមរយៈយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលបានចាត់ទុកថា ការធ្វើឲ្យរស់ឡើងវិញនូវប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលជាកត្តាសំខាន់ណាស់សម្រាប់ការអភិវឌ្ឍន៍ដែលមានមូលដ្ឋានដ៏ទូលំទូលាយ ហើយមើលឃើញការកែ លម្អការអប់រំ និងការបណ្តុះបណ្តាលជាវិភាគទានចំបងសម្រាប់ការកសាងជាតិទាំងមូល ព្រមទាំង ប្រជាធិបតេយ្យភាវូបនីយកម្ម និងសេរីភាវូបនីយកម្មសេដ្ឋកិច្ច។ ជាងនេះទៅទៀត ដោយ

---

[6]មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[7]មាត្រា៦៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[8]មាត្រា៦៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[9]មាត្រា៦៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[10]មាត្រា៦៨ កថាខណ្ឌទី១ និងទី២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[11]មាត្រា៧៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ឃើញថា ស្ត្រីផងដែរបានដើរតួនាទីសំខាន់នៅក្នុងសង្គមបន្ទាប់ពីបុរស តែដោយសារតែការទទួលរងនូវឥទ្ធិពល ពីអតីតកាលធ្វើឲ្យស្ត្រីគឺពុំបានទទួលបានការអប់រំបានច្រើន។ ម្យ៉ាងទៀតដោយសារប្រព័ន្ធគឺមិនទាន់ មានលក្ខខណៈសមរម្យ។

ដូចនេះរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយយុទ្ធសាស្ត្រចតុកោណដូចតទៅៈ

### ១.២.១ គោលនយោបាយយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១

នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលដំបូងនេះ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ដើម្បីបង្កើនសមត្ថភាពធនធានមនុស្សឲ្យមានប្រសិទ្ធិភាពខ្ពស់ទៅនឹងជំនាញផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅក្នុងក្របខ័ណ្ឌនៃភាពជាសហគ្រិន និងមានគំនិតច្នៃប្រឌិតខ្ពស់ មានក្រមសីលធម៌ក្នុងវិជ្ជាជីវៈ និងមានភាពស្មោះត្រង់ដើម្បីជម្រុញឲ្យមានការអភិវឌ្ឍ ។

ជាក់ស្តែងក្នុងការអនុវត្តយុទ្ធសាស្ត្រ " អប់រំសម្រាប់ទាំងអស់គ្នា "[12] ដោយរាជរដ្ឋាភិបាលផ្តល់នូវអាទិភាពខ្ពស់បំផុត ឲ្យមានកាតព្វកិច្ចសិក្សា ០៩ឆ្នាំ សំរាប់ការអប់រំមូលដ្ឋាន ដែលមានគុណភាពខ្ពស់ ពីព្រោះរាជរដ្ឋាភិបាលបានទទួលស្គាល់ថា ការអប់រំប្រកបដោយប្រសិទ្ធិភាពនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ មានផលប្រយោជន៍ខ្ពស់បំផុតខាង ផ្នែកសេដ្ឋកិច្ច និងសង្គម ពិសេសសម្រាប់នារីភេទ។ គេទទួលស្គាល់ថា មាតាដែលមានការអប់រំមានកូនតិច ហើយកូនដែលគេចិញ្ចឹម បានទទួលការបីបាច់ថែរក្សាល្អ និងមានសុខភាពល្អ ហើយក៏ជាកុមារដែលអាចបានចូលរៀន និង រៀនសូត្របានក្នុងសាលា។ ជាងនេះទៅទៀតរាជរដ្ឋាភិបាលក៏បានធានាផងដែរថា កុមារក៏ដូចជា សិស្សានុសិស្សនៃគ្រួសារក្រីក្រនឹងបានទទួលបានការអប់រំ ដោយផ្តល់អាហារូបករណ៍បន្ថែមដល់ ពួកគេ។ ព្រមទាំងស្តារឡើងវិញនូវសីលធម៌ និងប្រសិទ្ធភាពនៃការបង្រៀនតាមរយៈការកែលម្អ ប្រាក់បៀវត្ស និងការផ្គត់ផ្គង់សម្ភារៈសម្រាប់បង្រៀន និងសិស្សានុសិស្ស ដូចជា សម្ភារៈក្នុងបណ្ណាល័យ និងមន្ទីពិសោធន៍ ពិសេសនោះគឺ សាងសង់នូវអន្តេវាសិកដ្ឋានសម្រាប់សិស្សនិស្សិត ពិសេស សម្រាប់សិស្ស និស្សិតដែលជានារីភេទ ពីព្រោះនេះជាផ្នែកមួយដែលអាចបង្កភាពងាយស្រួល ក៏ ដូចជាសុវត្ថិភាពដល់ពួកគេដែលមកទទួលការអប់រំ នៅឆ្ងាយពីគេហដ្ឋាន និងបង្កើនចំនួនស្ថាប័ន អប់រំសាធារណៈឲ្យបានច្រើន។ ដើម្បីឲ្យការអនុវត្តន៍មានភាពរីកចម្រើនរាជរដ្ឋាភិបាលប្តេជ្ញាបែងចែក ចំណែកនៃធនធានជាតិ សំរាប់វិស័យអប់រំច្រើនជាងមុន និងគៀងគរធនធានបន្ថែមដោយផ្ទាល់ និងប្រយោលពីសហគមន៍ជាតិនិងអន្តរជាតិ ។

[12]ចតុកោណទី៤.មុំទី១ នៃ«យុទ្ធសាស្ត្រចតុកោណ» ដំណាក់កាលទី១ នីតិកាលទី៣ នៃរដ្ឋសភា

### ១.២.២ គោលនយោបាយយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២

នៅក្នុងដំណាក់កាលនេះរាជរដ្ឋាភិបាលបានអនុវត្តយុទ្ធសាស្ត្រ "អប់រំសម្រាប់ទាំងអស់គ្នា"[13] តាមរយៈការធានាសមធម៌ ក្នុងការអប់រំមូលដ្ឋានរយៈពេល ០៩ឆ្នាំ សម្រាប់កុមារគ្រប់រូប។ ជាក់ស្តែងនោះគឺ រាជរដ្ឋាភិបាលបានសម្រេចនូវសមិទ្ធផលធំៗ ដែលនៅក្នុងនោះរួមមាន: ចំនួនសាលារៀន និងគ្រូបង្រៀន ព្រមទាំងអាត្រាចុះឈ្មោះចូលរៀន នៅគ្រប់កម្រិតសិក្សានៃចំណេះទូទៅបានកើនឡើងជាលំដាប់ ពិសេសនៅតាមជនបទ ដោយឡែកអនុវិទ្យាល័យ ត្រូវបានបង្កើតឡើងនៅស្ទើរគ្រប់ឃុំ-សង្កាត់ទូទាំងប្រទេស។ ចំនួនគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស និងគ្រឹះស្ថានឧត្តមសិក្សា ព្រមទាំងចំនួនបុគ្គលិកបង្រៀន ក៏បានកើនឡើងស្របគ្នាដែរ។ ទទឹមនឹងនេះ រាជរដ្ឋាភិបាលបានបង្កើនថវិកាយ៉ាងច្រើនសម្រាប់វិស័យអប់រំ។ ក្នុងនីតិកាលទី០៣ កន្លងទៅនេះ ថវិកាចំណាយចរន្តសម្រាប់វិស័យអប់រំបានកើនឡើងទ្វេរដង ក្នុងឆ្នាំ២០០៧ ធៀបទៅនឹងឆ្នាំ ២០០៣ បើគិតជាភាគរយនៃថវិកា ចរន្តសរុបថវិកាចរន្តសម្រាប់វិស័យអប់រំមានប្រមាណ ១៩,២%។ រាជរដ្ឋាភិបាលសម្រេចបានជោគជ័យគួរជាទីមោទនៈ ក្នុងការលើកកម្ពស់ភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍នៅក្នុងវិស័យអប់រំនេះរួមទាំងដៃគូផ្លូវការវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល។

ដូច្នេះដើម្បីបន្តធ្វើឲ្យសមិទ្ធផលនេះកាន់តែមានភាពប្រសើរឡើង រាជរដ្ឋាភិបាលនឹងបន្តអនុវត្ត ផែនការយុទ្ធសាស្ត្រវិស័យអប់រំជាបន្តទៀត ដោយផ្តោតលើការផ្តល់ឱកាសស្មើៗ គ្នាដល់កុមារ និង យុវជនកម្ពុជាទាំងអស់ក្នុងការទទួលការអប់រំមូលដ្ឋាននៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត និងឋានៈ នៅក្នុងសង្គមឡើយ។ ទាំងនេះជាអ្វីដែលអាចបញ្ជាក់ឲ្យឃើញថាទាំងស្ត្រី និងបុរសគឺមានសិទ្ធិស្មើ គ្នាក្នុងការទទួលបានការអប់រំ។ ម្យ៉ាងវិញទៀតការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវផ្សារភ្ជាប់នឹង ការអប់រំ វប្បធម៌សន្តិភាព ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរបស់មនុស្ស ការគោរពគោលការណ៍សេរី ភាពប្រជាធិបតេយ្យ និងយុត្តិធម៌ ដោយប្រឆាំងនឹងអំពើហិង្សា ប្រឆាំងនឹងការប្រើប្រាស់គ្រឿង ញៀន ការជួញដូរកុមារ ស្ត្រី និងការរើសអើងគ្រប់ប្រភេទក្នុងសង្គម។

រាជរដ្ឋាភិបាលបានចាត់ទុកស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិទាំងមូល។ ដូចនេះយើងឃើញថារាជរដ្ឋាភិបាលបានកាត់បន្ថយគម្លាតយេនឌ័រក្នុងវិស័យអប់រំ ដែលជាបញ្ហាដ៏ធំរបស់ស្ត្រីតាមរយៈការបង្កើនការចុះឈ្មោះចូលរៀនរបស់កុមារី។ ម្យ៉ាងមួយវិញទៀត កត្តាតំបន់ កត្តាគ្រួសារ និងកត្តាសាលារៀន ក៏ជាបញ្ហាចោទសំរាប់នារីផងដែរ។ ដូច្នេះ ដើម្បីបញ្ហាសន្ធវរាល់បញ្ហា

[13]ចតុកោណទី៤.មុំទី១ នៃ«យុទ្ធសាស្ត្រចតុកោណ» ដំណាក់កាលទី២ នីតិកាលទី៤ នៃរដ្ឋសភា

ទាំងនេះ កុំឲ្យកើតមានឡើងនៅក្នុងនីតិកាលទី៥នេះរាជរដ្ឋាភិបាលនឹងបន្តការអនុវត្តគោលនយោបាយបង្កើតកាលានុវត្តភាពឲ្យសិស្ស-និស្សិតនារី បានចូលរៀនឲ្យបានកាន់តែច្រើន តាមរយៈ ការបង្កើនអាហារូបករណ៍សម្រាប់សិស្ស-និស្សិតនារី ក៏ដូចជាកម្មវិធីបំប៉ននៅគ្រឹះស្ថានសិក្សាការផ្តល់កន្លែងស្នាក់នៅ និងការធានាសុវត្ថិភាពសិស្ស-និស្សិតនារី និងការបង្កើនចំនួនគ្រូបង្រៀនជាស្ត្រី ។

ម្យ៉ាងទៀត ដើម្បីធានាឲ្យគុណភាពនៃការអប់រំទទួលបានភាពរីចម្រើន រាជរដ្ឋាភិបាលប្តេជ្ញាសម្រេចឲ្យបានលើការកែលម្អគុណភាពអប់រំឲ្យមានប្រសិទ្ធិភាពខ្ពស់ ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារតាមរយៈការលើកទឹកចិត្តគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា ការលើកទឹកចិត្តសិស្សពូកែការបណ្តុះបណ្តាលគ្រូបង្រៀន និងបំប៉នវិធីសាស្ត្របង្រៀន ព្រមទាំងការកែលម្អលក្ខខណ្ឌនៃការសិក្សា និងការផ្គត់ផ្គង់សម្ភារៈសិក្សា ការបង្កើតបណ្ណាល័យ មន្ទីរពិសោធន៍។ ក្នុងទិសដៅធានាកាលានុវត្តភាពប្រកបដោយសមធម៌ សាងសង់សាលារៀនគ្រប់កម្រិតសិក្សា ពិសេសនៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល និងការបង្កើតអាហារូបករណ៍សម្រាប់សិស្ស-និស្សិតក្រីក្រ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយគុណភាពឲ្យបានគ្រប់គ្រាន់ និងអនុវត្តគោលនយោបាយពង្រាយគ្រូឲ្យមានប្រសិទ្ធភាព ។

រារដ្ឋាភិបាល និងលើកទឹកចិត្តឲ្យគ្រូបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ និងគ្រូដែលបានបន្តរៀនចប់បរិញ្ញាប័ត្របានប្រឡងចូលក្របខ័ណ្ឌ គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ ដោយគ្មានកម្រិតអាយុ និងបង្គលក្ខណៈសម្បត្តិឲ្យគ្រូបឋមសិក្សា ដែលមិនទាន់មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ មានលទ្ធភាពប្រឡងយកសញ្ញប័ត្រសមមូលមធ្យមសិក្សាទុតិយភូមិ ដើម្បីបើកឱកាសឲ្យពួកគាត់មានលទ្ធភាពរៀននៅថ្នាក់ឧត្តសិក្សា ឬក្រោយឧត្តសិក្ស និងផ្លាស់ប្តូរនូវកាំប្រាក់បៀវត្សរ៍។

រាជរដ្ឋាភិបាល នឹងបន្តពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន ព្រមទាំងសហាគមន៍ជាតិ និង អន្តរជាតិដើម្បីបង្កើន និងលើកកម្ពស់គុណភាពសេវាអប់រំក្នុងនោះមានការយកចិត្តទុកដាក់បន្ថែមលើ ការបណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យា និងភាសាបរទេស ទាំងក្នុងគ្រប់កម្រិតមធ្យមសិក្សាចំណេះទូ ទៅទាំងក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស និងទាំងក្នុងកម្រិតឧត្តមសិក្សា ឲ្យស្របទៅនឹងស្តង់ដាអន្តរជាតិ និងតម្រូវការអភិវឌ្ឍន៍របស់ប្រទេស។ ពិសេសជាងនេះទៅទៀត ក្នុងកម្រិត មធ្យមសិក្សាបច្ចេកទេស និងឧត្តមសិក្សារាជរដ្ឋាភិបាលបន្តផ្តោតការយកចិត្តទុកដាក់ទៅលើការបណ្តុះ បណ្តាលវិស្វករ និងអ្នកបច្ចេកទេស។ ទន្ទឹមនឹងនេះ ដើម្បីកាត់បន្ថយគម្លាតរវាងការផ្គត់ផ្គង់ និងតម្រូវ ការការងារដែលរាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្សារភ្ជាប់ ទៅនឹងទីផ្សាពលកម្ម ដោយសហការយ៉ាងជិតស្និតជាមួយតួអង្គពាក់ព័ន្ធតាមរយៈវិធានការដូចតទៅ[14] ៖

[14]ចតុកោណទី៤.មុំទី១ នៃ«យុទ្ធសាស្ត្រចតុកោណ» ដំណាក់កាលទី២ នីតិកាលទី៥ នៃរដ្ឋសភា

- ផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋានដល់ប្រជាពលករនៅជនបទដើម្បីបង្កើនប្រាក់ចំណូល
- ផ្តល់ការបណ្តុះបណ្តាល ឬវិក្រឹតការដល់ពលករតាមរោងចក្រ ដោយសហការជាមួយនឹងនិយោជក
- បន្តជម្រុញការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយពង្រីកសេវានេះឲ្យទៅដល់ខេត្តក្រុង ក្នុងនោះមានរួមបញ្ចូលនូវការបណ្តុះបណ្តាលសហគ្រិនភាព នៅក្នុងកម្មវិធីផងដែរ។
- ការរៀបចំបង្កើតទីភ្នាក់ងារជាតិមុខរបរ និងការងារ និងមជ្ឈមណ្ឌលការងារតាមខេត្ត ក្រុង សម្រាប់ជាយន្តការសម្រួលដល់ការផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ។

រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការអប់រំក្រៅប្រព័ន្ធតាមរយៈកម្មវិធីអក្ខរកម្ម និងអក្ខរកម្មវិជ្ជាជីវៈ បង្កើតការសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍ ព្រមទាំងអនុវត្តកម្មវិធីសមធម៌។ រាជរដ្ឋាភិបាលនឹងបន្តបង្កើនចំណាយថវិកា និងគៀងគរហិរញ្ញប្បទានឲ្យបានច្រើនថែមទៀត សម្រាប់គាំទ្រការអប់រំដើម្បីធានាគុណភាពអប់រំឲ្យកាន់តែមានកម្រិតខ្ពស់ និងប្រកបដោយប្រសិទ្ធិភាព។

### ១.២.៣ គោលនយោបាយយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣

ទទឹមនឹងនេះ កម្ពុជានៅជួបបញ្ហាប្រឈមមួយចំនួនជាអាទិ៍ ភាពចាំបាច់ក្នុងការបន្តពង្រឹងគុណភាពអប់រំនៅគ្រប់កម្រិតសិក្សា អត្រាបោះបង់ការសិក្សារបស់សិស្សានុសិស្សនៅមានកម្រិតខ្ពស់នៅឡើយពិសេសនៅកម្រិតមធ្យមសិក្សា ភាពចាំបាច់ក្នុងការពង្រឹងការអភិវឌ្ឍន៍ជំនាញបច្ចេកទេសសម្រាប់យុវជនចំនួននិស្សិតសិក្សាផ្នែកវិស្វកម្មវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅមានចំនួនមិនទាន់គ្រប់គ្រាន់សម្រាប់ឆ្លើយតបទៅនឹងសេចក្តីត្រូវការទីផ្សារ និងការអភិវឌ្ឍន៍ប្រទេសនៅឡើយនិងភាពចាំបាច់ក្នុងការបន្តលើកទឹកចិត្ត និងបន្តពង្រឹងសមត្ថភាពគ្រូបង្រៀន ក៏ដូចជាពង្រឹងសមត្ថភាពនៃ គ្រឹះស្ថានសិក្សាតាមរយៈការបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈឧបទ្ទេសសិក្សាចាំបាច់។

ដោយផ្អែកទៅលើមូលដ្ឋានខាងលើនេះ រាជរដ្ឋាភិបាលនីតិកាលទី០៥ នឹងបន្តជម្រុញអនុវត្ត គោលការណ៍ "ការអប់រំសម្រាប់ទាំងអស់គ្នា[15]" សំដៅធានាសមធម៌ ក្នុងការទទួលបានសេវាអប់រំបន្តលើកកម្ពស់គុណភាព និងប្រសិទ្ធិភាពសេវានៃការអប់រំគ្រប់កម្រិត ព្រមទាំងបន្តអភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអប់រំ។

ក្នុងទិសដៅនេះ រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងផ្តោតអាទិភាពលើ៖

[15]ចតុកោណទី៤.មុំទី១ នៃ«យុទ្ធសាស្ត្រចតុកោណ» ដំណាក់កាលទី៣នីតិកាលទី៥ នៃរដ្ឋសភា

- ការបន្តរៀបចំ និងកែលម្អគោលនយោបាយ និងយុទ្ធសាស្ត្រវិស័យអប់រំ ជាពិសេសការធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការមេបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ក្នុងវិស័យអប់រំ និងគោលនយោបាយស្តីពីការអភិវឌ្ឍន៍ការស្រាវជ្រាវក្នុងវិស័យអប់រំ ដើម្បីកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ក្នុងគ្រប់វិស័យសំដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច និងពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិដោយផ្អែកលើអភិក្រមបុរេសកម្ម
- ការលើកកម្ពស់ការយល់ដឹង និងសមត្ថភាពធនធានមនុស្ស ក្នុងផ្នែកវិទ្យាសាស្ត្រ និងបច្ចេក- វិទ្យា ពិសេសតាមវិស័យអាទិភាពនានា ដូចជាវិស័យកសិកម្ម រួមមានដំណាំកសិកម្ម ការ ចិញ្ចឹមសត្វ និងវារីវប្បកម្មវិស័យឧស្សាហកម្មថាមពល សំណង់ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត វិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍វិស័យបរិស្ថានជាដើម តាមរយៈវិធានការគន្លឹះ មួយសចំនួនជាអាទិ៍[16]៖
    - ការបញ្ជ្រាបការយល់ដឹងអំពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងផលប្រយោជន៍នៃការប្រើប្រាស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត ពិសេស កម្រិត មធ្យមសិក្សាទុតិយភូមិ កម្រិតបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងនៅកម្រិត ឧត្តមសិក្សា
    - ជម្រុញការស្រាវជ្រាវ និងការអភិវឌ្ឍន៍រួមទាំងការបង្កើតបណ្តាញស្រាវជ្រាវគំរូរវាងសាកលវិទ្យាល័យ ស្ថាប័នរដ្ឋ ឧស្សាហកម្ម។
- ការបង្កើនលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ តាមរយៈការបន្តជំរុញការកសាងសាលាបឋមសិក្សាឲ្យដល់ភូមិ ការកសាងអនុវិទ្យាល័យឲ្យបានមួយយ៉ាងតិចក្នុងឃុំនីមួយៗ ស្របតាមស្ថានភាពភូមិសាស្ត្រ ការជម្រុញឲ្យមានសាកលវិទ្យាល័យ ឬសាខាសាកលវិទ្យា-ល័យនៅតាមខេត្តនីមួយៗ ស្របតាមលទ្ធភាព និងស្ថានភាពជាក់ស្តែង ការពង្រាយគ្រូ បង្រៀនឲ្យដល់គ្រប់ទីកន្លែងក្នុងនេះ រួមមានការផ្តល់អាទិភាពឲ្យគ្រូបង្រៀនអាចធ្វើការនៅតាមមូលដ្ឋានភូមិ ឃុំរបស់ខ្លួន ការបង្កើនចំនួនអន្តរវាសិកដ្ឋាន ការកាត់បន្ថយចំណាយ របស់មាតា-បិតាសិស្ស ការបង្កើនចំណាយសម្រាប់គ្រឹះស្ថានសិក្សា ព្រមទាំងការពង្រឹងការ ចូលរួមពីវិស័យឯកជន និងដៃគូអភិវឌ្ឍពាក់ព័ន្ធផ្សេងទៀត។

[16]ចតុកោណទី៤.មុំទី១ នៃ«យុទ្ធសាស្ត្រចតុកោណ» ដំណាក់កាលទី៣នីតិកាលទី៥ នៃរដ្ឋសភា

- ការបន្តការអភិវឌ្ឍន៍ស្ថាប័ន និងសមត្ថភាពរបស់មន្ត្រីអប់រំ តាមរយៈការអភិវឌ្ឍន៍ក្របខណ្ឌគតិយុត្ត និងការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ការពង្រឹងរចនាសម្ព័ន្ធការងារ និងការបណ្តុះបណ្តាលជំនាញដល់មន្ត្រី។
- ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំនៅគ្រប់កម្រិតសិក្សា និងក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងមុខជំនាញ ក្នុងគ្រឹះស្ថានរដ្ឋ និងគ្រឹះស្ថានឯកជន ឲ្យស្របតាមកម្រិតស្តង់ដារអន្តរជាតិ និងតម្រូវការអភិវឌ្ឍរបស់ប្រទេស តាមរយៈការពង្រឹងការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា ការធ្វើអធិការកិច្ច និងការពង្រឹងសមត្ថភាពគ្រប់គ្រង ការលើកទឹកចិត្តគ្រូបង្រៀនសមត្ថភាពបង្រៀន ការពង្រឹងគុណភាពក្នុងការប្រឡងបញ្ចប់កម្រិតសិក្សានីមួយៗ ការលើកកម្ពស់ការសិក្សាភាសាបរទេសដែលចាំ បាច់ ការកែលម្អលក្ខខណ្ឌនៃការសិក្សា ការបង្កើតបណ្ណាល័យ មន្ទីរពិសោធន៍ និងការបង្កើនការផ្គត់ផ្គង់សម្ភារៈសិក្សាព្រមទាំងការចូលរួមរបស់មាតាបិតាអាណាព្យាបាលរួមទាំងសហគមន៍។
- ការបន្តជម្រុញលើកម្ពស់តួនាទីសាសនា ពិសេសគឺព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋក្នុងការចូលរួមផ្តល់ការអប់រំផ្នែកគុណធម៌ សីលធម៌ និងចរិយាធម៌ ព្រមទាំងក្នុងការធានាភាពសុខដុមរមនានៅក្នុងសង្គមកម្ពុជា។
- ការជម្រុញរៀបចំ និងអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សំដៅលើកកម្ពស់ផលិតភាពការងាររបស់ពលករ ដោះស្រាយ និងកាត់បន្ថយភាពគ្មានការងារធ្វើរបស់យុវជន ព្រមទាំងបង្កើនចំណូលរបស់ប្រជាជន និងធានាសមធម៌។
- ការបន្តពង្រឹងគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការអភិវឌ្ឍន៍សម្រាប់យុវជននូវជំនាញបច្ចេកទេស និងជំនាញទន់ ពិសេសការធ្វើការងារជាក្រុម ការគោរពវិន័យ និងក្រមសីលធម៌វិជ្ជាជីវៈក្នុងកន្លែងការងារ តាមរយៈការកែលម្អកម្មវិធីបណ្តុះបណ្តាល ការបង្កើតស្តង់ដារជាតិសមត្ថភាព ការត្រួតពិនិត្យ និងធ្វើតេស្តសមត្ថភាព ការទទួលស្គាល់មុខជំនាញ ការអភិវឌ្ឍន៍មុខជំនាញ និងការប្រកួតប្រជែងជំនាញសំដៅ ឆ្លើយតបបានទៅនឹងសេចក្តីត្រូវការទីផ្សារពលកម្ម បង្កើនឱកាសទទួលបានការងារនិងប្រើប្រាស់ឲ្យអស់សក្តានុពល នូវផលលាភប្រជាសាស្ត្ររបស់កម្ពុជា ក៏ដូចជាដើម្បីបង្កើតលក្ខខណ្ឌសមស្របសម្រាប់ពលករកម្ពុជាអាចឈានឡើងទៅកាន់តួនាទីគ្រប់គ្រង និងដឹកនាំ។

## ១.៣ ផែនការនៃការអនុវត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា

ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់រាជរដ្ឋាភិបាល ដើម្បីជម្រុញកំណើនបង្កើតការងារធានាសមធម៌ និងប្រសិទ្ធភាពឲ្យស្របតាមនិន្នាការរីកចម្រើនរបស់សកលលោក និងដើម្បីឆ្លើយតបទៅនឹងអាទិភាព និងគោលនយោបាយអភិវឌ្ឍជាតិផែនការយុទ្ធសាស្ត្រវិស័យអប់រំត្រូវបានកសាងឡើង ដើម្បីបង្កើនកិច្ចប្រឹងប្រែង របស់វិស័យអប់រំឈានទៅសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា និងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ជាពិសេសដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ក៏ដូចជាជួយលើកកម្ពស់ស្មារតីឲ្យនារីភេទក្នុងការទទួលបានការអប់រំ។ ដូចនេះក្រសួង អប់រំ យុវជន និងកីឡា បានបង្កើតឲ្យមាននូវផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដែលបង្ហាញពីដំណាក់ កាលសំខាន់ៗក្នុងការធ្វើឲ្យមានកំណែទម្រង់អប់រំនៅកម្ពុជាដូចតទៅ៖

### ១.៣.១ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣

ដោយយោងទៅតាមមាត្រា៤៨នៃរដ្ឋធម្មនុញ្ញធានានូវសិទ្ធិទទួលបានការអប់រំសម្រាប់កុមារទាំងអស់៖ "រដ្ឋធានាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធ [...] ទទួលបានការអប់រំរៀនសូត្រ [...]។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឲ្យខូចដល់ការអប់រំនិងការរៀនសូត្ររបស់កុមារឬដែលនាំទ្រអន្តរាយដល់សុខភាព ឬសុខុមាលភាពកុមារ"

ដើម្បីអនុវត្តតាមបញ្ញត្តិរដ្ឋធម្មនុញ្ញមួយនេះ រាជរដ្ឋាភិបាលបង្កើតនូវគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្នុងគោលបំណងផ្តល់ឲ្យបានស្មើភាពគ្នា នូវលទ្ធភាពទទួលបានការអប់រំ។ ជាក់ស្តែង ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩-២០១៣ ដែលអនុម័តក្នុងឆ្នាំ២០១០ ដោយផ្តោតលើការផ្តល់ឱកាសស្មើៗគ្នាដល់កុមារ និងយុវជនកម្ពុជាទាំងអស់ ក្នុងការទទួលការអប់រំមូលដ្ឋាននៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត និងឋានៈនៅក្នុងសង្គមឡើយ។[17] ម្យ៉ាងទៀត ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវផ្សារភ្ជាប់នឹងការអប់រំវប្បធម៌ សន្តិភាព ការគោរពសិទ្ធ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការគោរពគោលការណ៍សេរីភាព ប្រជាធិបតេយ្យ និងយុត្តិធម៌ដោយប្រឆាំងនឹងអំពើហិង្សា ប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន ការជួញដូរ កុមារ និងស្ត្រី និងការរើសអើងគ្រប់ប្រភេទក្នុងសង្គម។

[17]ក្រសួងអប់រំ យុវជន និងកីឡា របស់រាជរដ្ឋាភិបាល "ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩-២០១៣(ថ្ងៃទី២០ខែកញ្ញា ឆ្នាំ២០១០)

នៅឆ្នាំ ២០០៨ រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៤ របស់រដ្ឋសភាពជាតិបានពិនិត្យមើលឡើងវិញលើផែនការនានារបស់ខ្លួន ដើម្បីអនុវត្តគោលនយោបាយអាទិភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ ដោយរក្សាទុក "ការពង្រឹងគុណភាព" ជាមុំទី១ ក្នុងចតុកោណទី ៤ ដែលមាន "ការកសាងសមត្ថភាពនិងអភិវឌ្ឍធនធានមនុស្ស" ជាស្នូល ។

ដើម្បីសម្រេចគោលដៅនៃគោលនយោបាយជាអាទិភាពយើងឃើញថាក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តអនុវិធានការសមស្របនៅក្នុងគោលនយោបាយទាំងបី នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំដែលសំដៅ:[18]

- ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ តាមរយៈកិច្ចខិតខំកសាងសាលារៀនឲ្យបានកាន់តែជិតផ្ទះប្រជាពលរដ្ឋ កាត់បន្ថយចំនួនសាលាបឋមសិក្សាមិនគ្រប់កម្រិតជាមួយនឹងការផ្តត់ផ្គង់ថវិកាដំណើរការគ្រឹះស្ថានសិក្សា ការផ្តល់គ្រូបង្រៀនឲ្យបានគ្រប់គ្រាន់ គ្រប់ទីកន្លែង និងសាងសង់ផ្ទះស្នាក់នៅរបស់គ្រូបង្រៀន អន្តេវាសិកដ្ឋានសម្រាប់សិស្ស-និស្សិតនៅតាមតំបន់ជួបការលំបាក ជាពិសេសសម្រាប់សិស្ស-និស្សិតជានារី។ ការផ្តល់សេវាអប់រំនឹងត្រូវពង្រឹងដល់កុមារក្នុងវ័យសិក្សានៅមត្តេយ្យសិក្សា ក៏ដូចជាកុមារពិការ និងជន ជាតិភាគតិច។ ការធានាឲ្យមានការចូលរួមពីសំណាក់សហគមន៍ និងផ្នែកឯកជននៅក្នុង ដំណើរការនេះមានសារៈសំខាន់ណាស់សម្រាប់ភាពជោគជ័យរយៈពេលវែង។
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ តាមរយៈការបង្កើនការផ្គត់ផ្គង់សម្ភារៈសិក្សាបណ្ណាល័យ និងបន្ទប់ពិសោធន៍បន្តជម្រុញការអនុវត្តកំណែទម្រង់កម្មវិធីសិក្សា និងការបង្កើនម៉ោងសិក្សា ព្រមទាំងផ្តល់អាហារូបករណ៍ ដល់សិស្ស (ជាថវិកា និងស្បៀង)-និស្សិតក្រីក្រឲ្យបានច្រើនថែមទៀត។ លើកកម្ពស់សមត្ថភាពលើការបង្រៀន និងការគ្រប់គ្រង ការពង្រឹងការគោរពក្រមសីលធម៌គ្រូបង្រៀន ការកែលម្អបរិស្ថានសាលារៀន ការផ្គត់ផ្គង់ទឹកស្អាត និងបង្គន់ អានាម័យ ពង្រីកសកម្មភាពការអប់រំតម្រង់ទិសមុខវិជ្ជាជីវៈបង្កើនសកម្មភាពអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុនិងការធានាគុណភាពអប់រំ។ ការពង្រឹងប្រព័ន្ធបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ការគ្រប់គ្រងវគ្គបំប៉ន និងការផ្សាភ្ជាប់ការងារទាំងនោះទៅនឹងឱកាសការងារ និងការដំឡើងឋានៈ នឹងជួយជំរុញលើកទឹកចិត្ត គ្រូបង្រៀន និងមន្ត្រីគ្រប់គ្រង។

[18]ក្រសួងអប់រំ យុវជន និងកីឡា របស់រាជរដ្ឋាភិបាល "ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩-២០១៣(ថ្ងៃទី២០ខែកញ្ញា ឆ្នាំ២០១០)

- អភិវឌ្ឍនស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ តាមរយៈការជម្រុញការកែលម្អរចនាសម្ព័ន្ធការងារកសាងច្បាប់ និងលិខិតបទដ្ឋានឲ្យបានគ្រប់គ្រាន់។ ជាមួយនោះធ្វើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់។ ការបន្តផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រព័ន្ធសវនកម្មផ្ទៃក្នុង ការកសាងផែនការ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ នឹងជម្រុញដល់ការអភិវឌ្ឍន៍ស្ថាប័ន និងសមត្ថភាពដើម្បីគ្រប់គ្រងប្រព័ន្ធទាំងនេះ។

- **យុទ្ធសាស្ត្រដើម្បីសម្រេចលទ្ធផល និង ចំណុចដៅនៃគោលនយោបាយរួមមានៈ**[19]

**គោនយោបាយទី១៖**

- ពង្រឹងកម្មវិធីអប់រំកុមារតូចសម្រាប់កុមារអាយុពី ៣ ទៅក្រោម ៦ឆ្នាំដោយផ្តោតមុខសញ្ញាទៅលើឃុំ ដែលមានអត្រាពិតចូលរៀនថ្មីទាប និងមានអាត្រាត្រួតថ្នាក់ខ្ពស់នៅបឋមសិក្សា។
- ធានាឲ្យកុមារអាយុ ៦ឆ្នាំបានចូលរៀននៅបឋមសិក្សា រួមបញ្ចូលទាំងក្រុមបាត់បង់ឱកាស ដូចកុមារពិការ កុមារជនជាតិភាគតិច ពលករកុមារជាដើម។
- កាត់បន្ថយបន្ទុកចំណាយរបស់មាតាបិតាសិស្សគ្រប់ទិដ្ឋភាព ដូចជាចំណាយក្រៅផ្លូវការជាដើម។
- បង្កើនចំនួនអាហារូបករណ៍ ដល់សិស្សមកពីគ្រួសារក្រីក្រ (ថវិការ ឬស្បៀង) សិស្សក្រីក្ររៀនពូកែ ជាពិសេសសិស្សស្រី ដើម្បីធានាបានការចូលរៀននៅសាលា បឋមសិក្សា និងមធ្យមសិក្សា។ កំណត់ឲ្យបានលើមុខសញ្ញាសិស្សបឋមសិក្សាក្រីក្រ ឬសុវត្ថិភាពស្បៀង សម្រាប់កម្មវិធីផ្តល់អាហារូបត្ថម្ភ និងកម្មវិធីអាហារូបករណ៍សម្រាប់សិស្សថ្នាក់ទី៧ ដល់ទី៩ ។
- ផ្តល់ការអប់រំបច្ចេកទេសវិជ្ជាជីវៈ ការអប់រំបំណិនជីវិត និងតម្រង់ទិសវិជ្ជាជីវៈនៅសាលារៀនចំណេះទូទៅ។
- ពង្រឹងការទទួលបានសេវាពីកម្មវិធីអភិវឌ្ឍយុវជនបាត់បង់ឱកាស។
- បង្កើនកាលានុវត្តភាពនៃការចូលរៀនប្រកបដោយសមធម៌នៅឧត្តមសិក្សា តាមរយៈការ បង្កើនចំនួនអាហារូបករណ៍សម្រាប់សិស្សអាទិភាព សិស្សពូកែ សិស្សក្រីក្រ សិស្ស

[19]ក្រសួងអប់រំ យុវជន និងកីឡា របស់រាជរដ្ឋាភិបាល "ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩-២០១៣(ថ្ងៃទី២០ខែកញ្ញា ឆ្នាំ២០១០)

មក ពីតំបន់ដាច់ស្រយាល និងសិស្សនារី ព្រមទាំងជំរុញឲ្យមានភាពជាដៃគូរវាងសាធារ-ណៈ និងដៃគូអភិវឌ្ឍ។

- បន្តសាងសង់សាលារៀនថ្មី និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬផ្តល់សម្ភារៈរូបវន្តបន្ថែមចំពោះសាលារៀនបឋមសិក្សាមិនគ្រប់កម្រិតថ្នាក់។
- ពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធកីឡាគ្រប់ប្រភេទនៅគ្រប់កម្រិត។
- ពង្រីកលទ្ធភាពចូលរួមរបស់ផ្នែកឯកជន និងសហគមន៍នៅគ្រប់កម្រិតសិក្សាជាពិសេស ក្រុមប្រឹក្សាឃុំ-សង្កាត់។
- ពង្រឹងភាពជាដៃគូរវាងរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍លើកាងារអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ នៅតាមតំបន់ព្រំដែន តំបន់ដាច់ស្រយាល តំបន់ជួបការលំបាកព្រម ទាំងបង្កើនការគាំទ្រចំពោះការផ្តល់បំណិនជីវិតមូលដ្ឋាន និងការបំប៉នជំនាញវិជ្ជាជីវៈមុខរបរចាំបាច់ដែលឆ្លើយតបនឹងតម្រូវការសង្គម និងទីផ្សារពលកម្ម។

- **គោលនយោបាយទី២៖ ការលើកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ**

- កាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សានៅគ្រប់កម្រិតថ្នាក់។
- កែលម្អគុណភាពនៃការបង្រៀន ការរៀននិងការស្រាវជ្រាវនៅគ្រប់កម្រិតក្នុងប្រទេស។
- អនុវត្តគោលនយោបាយកម្មវិធីសិក្សាថ្មីទាំងនៅបឋមសិក្សា និងនៅមធ្យមសិក្សាបឋមភូមិ ដោយផ្តោតការយកចិត្តទុកដាក់លើម៉ោងបង្រៀន។
- បង្កើតស្តង់ដានៃការសិក្សារបស់សិស្សនៅថ្នាក់ទី ៣ ទី៦ ទី ៩ ទូទាំងប្រទេស។
- លើកកម្ពស់ការអភិវឌ្ឍន៍គ្រូបង្រៀនទាំងការបណ្តុះបណ្តាល និងវិក្រឹតការ។
- បង្កើនរង្វាន់លើកទឹកចិត្ត និងប្រាក់លាភការជូនគ្រូបង្រៀន ផ្អែកលើលទ្ធផលបំពេញការងារ និងស្តង់ដា។
- បង្កើនគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈនិងការទទួលខុសត្រូវរបស់គ្រឹះស្ថានសិក្សា ក្នុងការប្រើប្រាស់ថវិកា និងការសម្រេចចិត្តលើកម្មវិធីនានា។
- បង្កើនតម្លាភាព និងកែលម្អពិនិត្យតាមដានការបំពេញការងារ និងការទទួលខុសត្រូវរបស់គ្រូបង្រៀន សាលារៀន និងគ្រឹះស្ថានឧត្តមសិក្សា។
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំបច្ចេកទេសវិជ្ជាជីវៈ ការអប់រំបំណិនជីវិត និងការងារតម្រង់ទិសវិជ្ជាជីវៈ។

- ពង្រឹង និងពង្រីកការងារសុខភាពសិក្សានៅតាមអង្គភាព និងគ្រឹះស្ថានសិក្សាគ្រប់កម្រិត និងគ្រប់លំដាប់ថ្នាក់។
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពកម្មវិធីអប់រំកាយ និងកីឡា។
- លើកកម្ពស់ការយល់ដឹង និងគាំទ្រអំពីសារៈសំខាន់របស់ការងារអប់រំកាយ និងកីឡា។
- បង្កើនគុណភាព និងប្រសិទ្ធភាពនៃកម្មវិធីអភិវឌ្ឍយុវជនតម្រង់ទៅរកការអភិវឌ្ឍន៍សង្គ- មសេដ្ឋកិច្ច។

- **គោលនយោបាយទី៣៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាព ជូនទៅដល់មន្ត្រីអប់រំ សម្រាប់ ធ្វើវិមជ្ឈការ**

- បង្កើនគុណភាព និងប្រសិទ្ធភាពនៃការកសាងផែនការ ពិនិត្យតាមដាន ពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្តន៍ផែនការ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ពង្រឹងការតម្រឹម សុខុដុមនីយកម្ម និងការសម្របសម្រួល ក្នុងការអភិវឌ្ឍន៍សមត្ថភាព ក្នុងវិស័យអប់រំដែលដឹកនាំដោយក្រសួង និងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ។
- រៀបចំលិខិតបទដ្ឋានគតិយុត្ត ឲ្យបានច្បាស់លាស់លើគ្រប់វិស័យ និងអនុវិស័យអប់រំទាំងអស់ស្របតាមច្បាប់ស្ដីពីការអប់រំ។
- ពង្រឹងការផ្ដល់សេវាសាធារណៈសម្រាប់វិស័យអប់រំ។
- កែលម្អមូលដ្ឋានសម្រាប់រៀបចំផែនការហិរញ្ញវត្ថុរយៈពេលមធ្យម និងការគ្រប់គ្រងបែបវិមជ្ឈិការ ព្រមទាំងកែលម្អប្រព័ន្ធច្បាប់ និងអភិបាលកិច្ចល្អ។
- ធានាថាគ្រប់អង្គភាព និងគ្រឹះស្ថានសិក្សាជាអង្គភាពប្រតិបត្តិប្រកបដោយប្រសិទ្ធភាព ក្នុងការគ្រប់គ្រង និងប្រើប្រាស់ថវិកា។
- កែលម្អការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន សម្រាប់ទំនើបកម្ម និងវិមជ្ឈការនៃប្រព័ន្ធរដ្ឋ-បាល និងត្រួតពិនិត្យ ដែលអាចឈានទៅដល់កម្រិតសាលារៀន។
- លើកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល។
- បង្កើនគុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ។
- ពង្រឹងប្រព័ន្ធតាមដាន ការងារហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- កាត់បន្ថយវិសមភាពយេនឌ័រ ក្នុងតំណែងអ្នកគ្រប់គ្រងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ១.៣.២ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨

គោលនយោបាយ យុទ្ធសាស្ត្រ សូចនាករស្នូល និងចំណុចដៅអប់រំ**គោលនយោបាយអប់រំ**[20]

- **គោលនយោបាយទី១៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌**

កុមារគ្រប់រូបបានទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាព បានចូលរៀននៅបឋមសិក្សា មធ្យមសិក្សា និងមានឱកាសបន្តការសិក្សាទៅមុខទៀត។ សម្រាប់កុមារដែលពុំមានលទ្ធភាព ចូលរៀនក្នុងប្រព័ន្ធ ជម្រើសផ្សេងទៀតនឹងត្រូវផ្តល់លទ្ធភាពឲ្យអ្នកទាំងនោះទទួលបានការអប់រំ ។

ការបង្កើនចំនួនកុមារនិងយុវជនឲ្យទទួលបានការអប់រំនៅគ្រប់កម្រិត ដោយផ្តោតលើសម-ធម៌ និងតំបន់ និងក្រុមកុមារជួបការលំបាក។ ការបង្កើនឱកាសដល់សិស្សដែលបញ្ចប់ការសិក្សានៅ ថ្នាក់ទី១២ ឲ្យទទួលបាននូវចំណេះដឹង និងជំនាញក្នុងការគិតនិងហេតុផល និងអាចជាមូលដ្ឋាន សម្រាប់បន្តការសិក្សានៅក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងឧត្តមសិក្សាតទៅទៀត។

- **គោលនយោបាយទី២ ៖ លើកម្ពស់គុណភាពនិងភាពឆ្លើយតប**

កុមារនិងយុវជនគ្រប់រូបមានបទពិសោធក្នុងការសិក្សា ប្រកបដោយគុណភាពនិងភាពឆ្លើយ តប ដែលអាចឲ្យពួកគេអាចចូលរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសជាតិ។

ការធានាថា ការអប់រំប្រកបដោយគុណភាព និងមានទំនាក់ទំនងទៅនឹងគោលដៅអភិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់ប្រទេស។ ក្របខណ្ឌគុណភាពដែលផ្តល់ដល់អ្នកសិក្សា មាតាបិតា សហគមន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រង ជាមួយនឹងស្តង់ដារនៃផលសម្រេច ការពិនិត្យតាមដាននឹងរបាយការ-ណ៍។

- **គោលនយោបាយទី៣៖ ធានាភាពស័ក្តសិទ្ធនៃភាពជាអ្នកដឹកនាំ និងពីការគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

ការផ្តល់សេវាអប់រំ ត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព និងទន់ភ្លន់។ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងវិជ្ជាជីវៈនឹងផ្តល់នូវតម្លៃដ៏ល្អបំផុត (ផ្តោតលើលទ្ធភាព) ទាន់ពេលវេលាការ ពិនិត្យតាមដាន និងរបាយការណ៍នូវលទ្ធផល និងយោបល់ត្រឡប់វិធានការប្រកបដោយគនេយ្យភាព និងយន្តការសម្រាប់កែលម្អគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ នឹងអាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការ ជាក់ស្តែងនៅកម្រិតសាលារៀន។

[20] ក្រសួងអប់រំ យុវជន និងកីឡា របស់រាជរដ្ឋាភិបាល "ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤-២០១៨(ថ្ងៃទី០៧ខែមីនា ឆ្នាំ២០១៤)

### ១.៣.៣ គោលការណ៍របស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨

ក្របខណ្ឌយុទ្ធសាស្ត្ររបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផ្តោតលើការបន្តសកម្មភាព ការពង្រីក និងការបន្តនិរន្តរភាពនៃសមិទ្ធផលដែលបានសម្រេចកន្លងមកទាក់ទងនឹងការចូលរៀន ការលើកកម្ពស់សមធម៌ ការបង្កើនគុណភាពនិងភាពឆ្លើយតបសម្រាប់កុមារនិងយុវជន តាមរយៈការផ្តល់ សេវាអប់រំប្រកបដោយវិជ្ជាជីវៈ តម្លាភាព និងគណនេយ្យភាព ។

ដើម្បីសម្រេចបានវត្ថុបំណងគោលនយោបាយនិងកម្មវិធីនានា ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

- ផ្សារភ្ជាប់ទៅនឹង កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ និងចូលរួមក្នុងដំណើរការបង្កើតរដ្ឋបាលឯកភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមការណែនាំពីគណៈកម្មការ ជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ។
- រៀបចំយន្តការប្រតិបត្តិទាំងក្នុងនិងក្រៅ និងប្រព័ន្ធការងារទាំងខ្សែទទឹងនិងខ្សែបណ្តោយ ប្រព័ន្ធព័ត៌មាន និងមុខងារប្រតិបត្តិ ដែលឆ្លុះបញ្ចាំងពីការគ្រប់គ្រងតាមបែបអនុវិស័យ និងស្របតាមវត្ថុបំណងគោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង។
- ឆ្លើយតបទៅនឹងក្របខណ្ឌនៃការកសាងផែនការ ការគ្រោងថវិកា ការពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល។
- ផ្អែកលើគោលការណ៍សិទ្ធិ និងសមធម៌។
- ផ្តល់ជាក្របខណ្ឌគុណភាពទូលំទូលាយមួយ នឹងដែលរួមបញ្ចូលទាំងការវាយតម្លៃលទ្ធផល សិក្សារបស់សិស្ស (ផ្សារភ្ជាប់នឹងការវាយតម្លៃនៅថ្នាក់តំបន់ និងអន្តរជាតិ) កម្មវិធីសិក្សា និង សម្ភារៈសិក្សាជំនាញ និងចំណេះដឹងក្នុងការបង្រៀន សម្ភារៈការគ្រប់គ្រង និងស្តង់ដាររបស់សេវា អប់រំ។
- លើកកម្ពស់និរន្តរភាពផ្នែកហិរញ្ញវត្ថុ តាមរយៈការធ្វើចំណោលផ្អែកតាមតម្រូវការ។
- កៀរគរការចូលរួមរបស់អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ។

## ផ្នែកទី២៖ ការទទួលបានសិទ្ធិតាមរយៈអង្គការក្រៅរដ្ឋាភិបាល

### ២.១ ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល(NGO Education Partnership)

បង្កើតឡើងក្នុងគោលបំណងដើម្បីពង្រឹងទំនាក់ទំនងរវាងអង្គការក្រៅរដ្ឋាភិបាលនិងក្រសួង អប់រំ យុវជន និងកីឡា ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ហៅកាត់(NEP) ត្រូវបានបង្កើត ឡើងនៅ ឆ្នាំ២០០១។ ជាលទ្ធផលរបស់សំណើរពីក្រុមការងារវិស័យអប់រំ ស្តីពីការទំនាក់

ទំនងរវាង អង្គការក្រៅរដ្ឋាភិបាលជាមួយនិងក្រសួងអប់រំ យុវជន និងកីឡា អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ត្រូវបានបង្កើតឡើងក្នុងគោលបំណង កសាងបណ្តាញទំនាក់ទំនងឲ្យកាន់តែរឹងមាំ រវាងអង្គការក្រៅរដ្ឋាភិបាល ធ្វើការលើវិស័យអប់រំដោយចេញនូវវត្ថុបំណង:

ជម្រុញឲ្យមានកិច្ចពិភាក្សារវាងអង្គការដែលជាសមាជិក និងរវាងអង្គការសមាជិក NEP ជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដែលំអរគុណភាពការអប់រំនៅកម្ពុជា។

ចាប់តាំងពីការបង្កើតឡើងនៅឆ្នាំ ២០០១ សមាជិកភាពរបស់ NEP បានកើនឡើងពី១៧ រហូតដល់៦៥អង្គការ។ ជាដំបូងអង្គការដែលជាសមាជិកភាគច្រើនមានទីស្នាក់ការនៅទីក្រុងភ្នំពេញ ប៉ុន្តែរយៈពេលពីរឆ្នាំកន្លងទៅនេះ NEP បានធ្វើកាយ៉ាងសកម្មក្នុងការជ្រើសរើសអង្គការជាសមាជិកនៅតាមខេត្តផ្សេងៗរួមមាន: បាត់ដដំបង ប៉ៃលិន កំពត កពង់ធំ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ សៀមរាប ក្រុងព្រះសីហនុ មណ្ឌលគីរី និងពោធិ៍សាត់។

### ២.១.១ ទំនាក់ទំនងជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា

ដើម្បីគោរពតាម បំណងប្រាថ្នារបស់សមាជិកខ្លួន NEPនៅតែថែរក្សាឯករាជ្យភាពរបស់ខ្លួន និងតួនាទីរបស់ខ្លួនក្នុងកិច្ចសហការ និងសហប្រតិបត្តិការជាមួយក្រសួងអប់រំយុវជន និងកីឡា ដើម្បី សម្រេចគោលបំណងរួមគ្នាក្នុងការកែលម្អគុណភាពការអប់រំនៅកម្ពុជា។ សមាជិកក្រុមប្រឹក្សាភិបាលរបស់ NEP បានធ្វើតំណាងឲ្យសមាជិករបស់ខ្លួនចូលរួមក្នុងកិច្ចប្រជុំនានារវាងក្រសួងម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល គណៈកម្មាធិការ និងក្រុមការងារមួយចំនួនមានដូចជា:

- ក្រុមការងារបច្ចេកទេសចំរុះវិស័យអប់រំ (JTWG-ED)
- ក្រុមការងារតូច (SWG)
- ក្រុមការងារវិស័យអប់រំ (ESWG)
- គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល សម្រាប់ការត្រួតពិនិត្យសូចនាករ កិច្ចប្រជុំពិគ្រោះយោបល់
- ក្នុងនាមជាសមាជិករបស់ក្រុមការងារខាងលើ NEP បានធ្វើការយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍ ឯកសារគោលនយោបាយថ្នាក់ជាតិមានដូចជា:
  - ផែនការយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS)
  - ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ(NSDP)
  - ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP)
  - កម្មវិធីគាំទ្រវិស័យអប់រំ(ESSP)

### ២.១.២ របាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាល

ការងារមួយក្នុងចំណោមការងារជាច្រើនដែល NEPទទួលអនុវត្តគឺ រៀបចំរបាយការណ៍អង្គការក្រៅរដ្ឋាភិបាល សម្រាប់ការពិនិត្យឡើងវិញលើកម្មវិធីគាំទ្រវិស័យអប់រំ។ របាយការណ៍នេះឆ្លុះបញ្ចាំងពីការចូលរួម របស់អង្គការក្រៅរដ្ឋាភិបាលក្នុងវិស័យអប់រំនៅកម្ពុជា និង លើកយកចំនុចសំខាន់ៗពីវិធីសាស្ត្រដែលអង្គការក្រៅរដ្ឋាភិបាលបានគាំទ្រ និងបំពេញឲ្យកម្មវិធីអប់រំជាតិ។ ក្នុងការរៀបចំរបាយការណ៍នេះ NEP ធ្វើអង្កេតលើសមាជិករបស់ខ្លួន និងបានប្រមូលទិន្នន័យស្តីពីការងារសម្រេចបានរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងវិស័យអប់រំ។ ដោយការសិក្សាអង្កេតនេះបានធ្វើយ៉ាងជិតដល់ធ្វើឲ្យលទ្ធផលនៃការវិភាគពីស្ថានភាពបច្ចុប្បន្ននៃវិស័យអប់រំដែលផ្តល់ដោយ អង្គការក្រៅរដ្ឋាភិបាលជាពត៌មានសារៈសំខាន់។ ទិន្នន័យបានពីការអង្កេត បានចងក្រងជាឯកសារដើម្បីមើលឃើញពីកម្រិតសេវាកម្មអប់រំដែលកំពុងផ្តល់ដោយផ្ទាល់ដោយអង្គការក្រៅរដ្ឋាភិបាល។ បន្ទាប់ មកពត៌មាននេះត្រូវបានយកមកវិភាគ និងប្រៀបធៀបជាមួយទិន្នន័យរបស់ក្រសួងក្នុងគោលបំណងរកឲ្យឃើញចន្លោះខ្វះខាតក្នុងការផ្តល់សេវាអប់រំទូទាំងប្រទេស។

លទ្ធផលពីរបាយការណ៍ អង្គការក្រៅរដ្ឋាភិបាល នឹងផ្តល់នូវមូលដ្ឋានសម្រាប់ការពិភាក្សាដែលកំពុងបន្តមានក្នុងវិស័យអង្គការក្រៅរដ្ឋាភិបាល និងរវាងអង្គការក្រៅរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា។

### ២.១.៣ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលទៅលើការអប់រំសម្រាប់ទាំងអស់គ្នា

អង្គការក្រៅរដ្ឋាភិបាលធ្វើការក្នុងវិស័យអប់រំនៅកម្ពុជាបានជួយដល់កុមារ យុវជន និងមនុស្សពេញវ័យដែលគ្មានលទ្ធភាពចូលរៀនក្នុងប្រព័ន្ធអប់រំរដ្ឋ ដោយមូលហេតុមួយចំនួន។ ក្នុងភាពជា ដៃគូជាមួយរដ្ឋាភិបាល និងម្ចាស់ជំនួយ អង្គការក្រៅរដ្ឋាភិបាលបានជួយលើការងារជាច្រើនដូចជា ការអប់រំថ្នាក់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ ការអភិវឌ្ឍន៍និងថែទាំកុមារតូច អប់រំក្រៅប្រព័ន្ធបំនិនជីវិត ការអប់រំសុខភាព កម្មវិធីផ្តល់ចំណីអាហារ និងកម្មវិធីអាហារូបករណ៍។

## ២.២ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(The Cambodian Women's Crisis Center)

អង្គការនេះបានបង្កើតនៅដើមឆ្នាំ ១៩៩៧ គឺជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលមិនស្វែងរកប្រាក់ចំណេញ និងមិនប្រកាន់យកគណៈបក្សនយោបាយ។ ហើយបេសកកម្មរបស់អង្គការនេះ គឺ លុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំង នឹងនារីភេទ ក្នុងខណៈពេលផ្តល់សេវាចំពោះជនរងគ្រោះទាំងអស់ដែលត្រូវបានរំលោភបំពាននូវមូលដ្ឋានយេនឌ័រ។

អង្គការនេះផងដែរ គឺធ្វើការដើម្បីប្រគល់សិទ្ធិអំណាចទៅឲ្យស្ត្រី និងក្មេងស្រីដែលងាយនឹងរងគ្រោះតាមរយៈផែនការយុទ្ធសាស្ត្រចំនួន៣ គឺៈ ការការពារ ការបង្កា និង ស្វែងរកការគាំទ្រដើម្បីជម្រុញឲ្យមានការលើកកម្ពស់សន្តិភាព និងសមភាពយេនឌ័រនៅក្នុងសង្គម ។

# ជំពូកទី ២ ៖
# ស្ថានភាពក្នុងការអនុវត្តន៍សិទ្ធិស្ត្រីក្នុងវិស័យអប់រំ ក្នុងកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយ

បន្ទាប់ពីបានធ្វើការបកស្រាយទៅលើច្បាប់ផ្សេងៗដែលមានដូចជា យុទ្ធសាស្ត្រចតុកោណ រួចមកហើយនោះ ខាងក្រោមនេះ យើងនឹងធ្វើការលម្អិតបន្ថែមទៀតជាមួយនឹង **គោលដៅក្នុងការបណ្តុះបណ្តាល** ស្ត្រីក្នុងវិស័យអប់រំនៅកម្ពុជា ដែលក្នុងនោះយើងនឹងសិក្សាទាក់ទងជាមួយនឹងការអប់រំបណ្តុះបណ្តាលទាំងនៅទីក្រុង និងតាមបណ្តាលខេត្តមួយចំនួននៅកម្ពុជា ក្នុងផ្នែកទី១ និងនៅក្នុងផ្នែកទី២ ធ្វើការរៀបរាប់អំពី **ការអភិវឌ្ឍន៍ និងឧបសគ្គនាពេលបច្ចុប្បន្ន**ដែលកំពុងតែជួបប្រទះ។

## ផ្នែកទី១៖ គោលដៅក្នុងការបណ្តុះបណ្តាល

ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌គឺជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងការប្រកួតប្រជែងរបស់កម្ពុជាទាំងក្នុងពេលបច្ចុប្បន្ន និងទាំងសម្រាប់អនាគត ពិសេសក្នុងពេលដែលសមាហរណកម្មអាស៊ានឆ្នាំ២០១៥ កាន់តែខិតចូលមកដល់ តម្រូវឲ្យមានការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាព ដើម្បីឆ្លើយតបទៅ នឹងសេចក្តីត្រូវការក្នុងការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចកម្ពុជា ដែលជាកត្តាគន្លឹះ សម្រាប់ទ្រទ្រង់កំណើន សេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេស។ ជាក់ស្តែងវិស័យអប់រំត្រូវបន្តផ្តោតអាទិភាពលើការ ពង្រឹងគុណភាព ភាពអាចឆ្លើយតបបានទៅនឹងសេចក្តីត្រូវការនៃទីផ្សារពលកម្ម និងការអភិវឌ្ឍន៍ ជំនាញបច្ចេកទេសសម្រាប់យុវជន ដើម្បីបង្កើតឱកាសការងារ និងប្រើប្រាស់ឲ្យអស់នូវសក្តានុពល នៃប្រជារាស្ត្រកម្ពុជាក៏ដូចជាដើម្បីធានាការបន្តវេនក្នុងការដឹកនាំនិងអភិវឌ្ឍប្រទេស។

ក្រឡេកមកវិញ យើងបានឃើញថាស្ត្រីក្នុងវិស័យអប់រំ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ដោយបានបង្កើតឱកាស ក្នុងការទទួលបានចំណូលតាមរយៈការធ្វើការងារខាងក្រៅ ឬ ប្រកបរបររកស៊ីដោយខ្លួនឯងវាមានសារៈសំខាន់ក្នុងការកែប្រែជីវភាពរបស់ខ្លួន។

រដ្ឋ ត្រូវលើកកម្ពស់ និងគាំទ្រដល់ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍន៍ ការច្នៃប្រឌិតសម្រាប់ការអប់រំ ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងស្របតាមសកលភាវូបនីយកម្មដើម្បីលើកស្ទួយសកម្មភាពធនធានមនុស្សនិងជម្រុញការអភិវឌ្ឍន៍ប្រទេសជាតិ។ រីឯក្រសួងទទួលបន្ទុកទៅលើវិស័យអប់រំវិញ ត្រូវកំណត់គោលការណ៍ស្តីពី ការអប់រំគ្រប់ភូមិសិក្សានៃប្រព័ន្ធអប់រំកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## ១.១ នៅទីក្រុង

ពាក្យថាទីក្រុងគឺជាទីប្រជុំជន ដែលមានមនុស្សរស់នៅកកកុញ និងមានភាពសម្បូរបែបជាជាងទីរួមខេត្ត។ មានសាលាសិក្សាជាច្រើន បាននឹងកំពុងតែធ្វើការបង្កើតថ្មីនៅប៉ុន្មានឆ្នាំចុងក្រោយនេះ នៅតាមទីកន្លែងដែលមានមនុស្សរស់នៅអ៊ូរអរ នឹងដែលគេគិតថាជាទីសមរម្យ គួរនឹងបើកឲ្យមានសាលា ដើម្បីឲ្យមានសិស្ស-និស្សិតក៏ដូចជាអ្នកមានបំណងចង់ចូលរៀនទាំងឡាយមានភាពងាយស្រួលអាចមករៀនបាន។ ក្នុងនោះការដែលបង្កើតឲ្យមានសាលារៀនផ្សេងៗមិនថាថ្នាក់មត្តេយ្យសិក្សា ថ្នាក់បឋមសិក្សា ថ្នាក់មធ្យម សិក្សាថ្នាក់វិទ្យាល័យ ថ្នាក់ឧត្តមសិក្សា និងថ្នាក់ផ្សេងៗទៀត សុទ្ធតែបង្កើតឡើង ក្នុងគោលបំណងជួយជម្រុញឲ្យមានការយល់ដឹងកាន់តែច្រើនក្នុងវិស័យអប់រំ។ យើងបានបែងចែកគ្រឹះស្ថានអប់រំជាពីរះ ទីមួយគឺ គ្រឹះស្ថានសាធារណៈ និងទីពីរ គ្រឹះស្ថានឯកជន។ ដែលគ្រឹះស្ថានទាំងពីរ សុទ្ធតែបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋ ក្នុងវិស័យអប់រំគ្រប់កម្រិត។

### ១.១.១ ការអប់រំនៅក្នុងគ្រឹះស្ថានសាធារណៈ

ដោយយើងបានឃើញថា ការអប់រំនៅក្នុងទីក្រុងគឺមានលក្ខណៈទូលាយជាងការអប់រំនៅឯតាមបណ្តាលខេត្តមួយចំនួន ដោយនៅទីក្រុងមានសាលាជាច្រើនបានបង្កើតឡើងដែលនេះជាផ្នែកងាយស្រួលមួយដល់ប្រជាជន ក្នុងការបញ្ជូនកូនៗរបស់ពួកគេឲ្យទៅសិក្សានៅសាលាដែលពួកគេមានលទ្ធភាពអាចរ៉ាប់រងបាន។ ក្នុងនោះគ្រឹះស្ថានសាធារណៈ គឺជាគ្រឹះស្ថានមួយដែលមិនតម្រូវឲ្យសិស្សធ្វើការចំណាយច្រើនទៅលើការបង់ថ្លៃសិក្សា ដូចជានៅគ្រឹះស្ថានឯកជននោះទេ ជាពិសេសសម្រាប់ការចុះឈ្មោះចូលរៀន គឺមិនតម្រូវឲ្យបង់ប្រាក់ទេ។ យ៉ាងណាមិញ យើងនឹងធ្វើការពិនិត្យទៅលើចំនួនសិស្ស និស្សិតនៅតាមបណ្តាលថ្នាក់ ដែលយើងនឹងធ្វើការពិនិត្យទៅលើចំនួនចូលរៀនរបស់ពួកគេ។ ដែលក្នុងនោះ យើងនឹងមើលថាតើនៅថ្នាក់មត្តេយ្យសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា មានចំនួនសិស្ស-និស្សិតស្រីដែលបានចូលរៀនមានចំនួនកើនឡើង ឬមួយក៏ធ្លាក់ចុះគួរឲ្យកត់សម្គាល់យ៉ាងណា នៅក្នុងចន្លោះប៉ុន្មានឆ្នាំចុងក្រោយនេះ។

#### ក.ថ្នាក់មត្តេយ្យសិក្សា

[21]ក្រោយឆ្នាំ១៩៧៩ សាលាមត្តេយ្យសិក្សា ត្រូវបានស្តារឡើងវិញ និងអភិវឌ្ឍជាបណ្តើរៗ។ ថ្នាក់មត្តេយ្យសិក្សា គឺជាថ្នាក់សិក្សាដែលធ្វើការបណ្តុះបណ្តាលចំពោះកុមារតូចៗ ក្នុងនោះមានទាំង ក្មេងស្រី និងក្មេងប្រុសដែលមានអាយុចន្លោះពី៣ ទៅដល់ ៥ឆ្នាំ ដែលនឹងបានបញ្ជូនទៅ

[21] គណៈកម្មាធិការជាតិ អប់រំសម្រាប់ទាំងអស់គ្នា របាយការណ៍ ស្តីពី ការពិនិត្យឡើងវិញការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ជាតិ ឆ្នាំ២០១៥ ទំព័រ ២៦ ចំណុច២.៥.១

សិក្សានៅ ថ្នាក់មត្តេយ្យសិក្សានេះ។ ដោយយោងតាមការស្រាវជ្រាវពីរបាយការណ៍ស្តីពី ការពិនិត្យឡើងវិញ ការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ជាតិឆ្នាំ២០១៥។ ផ្អែកតាមទិន្នន័យក្នុងតារាង២.៥.១ ការចូលរៀន របស់កុមារនៅមត្តេយ្យសិក្សាកើនពី ៥០.៤០៥ នាក់ក្នុងឆ្នាំសិក្សា២០០០-០១ ដល់ ១៣១.១៨៥នាក់ ក្នុងឆ្នាំសិក្សា២០១២-១៣។ នេះគឺជាតួលេខមួយដែលបង្ហាញចំពោះការកើនឡើង របស់កុមារដែល បានចូលរៀននៅសាលារៀន។

ការអប់រំកុមារតូច គឺជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍កម្មវិធីការគាំពារ និងអភិវឌ្ឍកុមារតូចចំពោះវិស័យអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងដោយសហការជាមួយគ្រប់ផ្នែកពាក់ព័ន្ធ ក្នុងនោះមានដៃគូរអភិវឌ្ឍសហគម៍ និងផ្នែកឯកជន។ ផែនការយុទ្ធសាស្ត្រ គោលនយោបាយ សកម្មភាពជាច្រើនបានដាក់ចេញ និងអនុវត្តជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ រួមមានផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា២០០៣-១៥ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និង សកម្ម- ភាពសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- ស្តង់ដាសិក្សារបស់កុមារអាយុ ៣ឆ្នាំ ៤ឆ្នាំ និង ៥ឆ្នាំ និងកម្មវិធីសិក្សាកុមារអាយុ ៥ឆ្នាំ
- ឯកសារធនធានស្តីពីការអភិវឌ្ឍន៍កុមារតូច
- កម្មវិធីអប់រំកុមារដែលមិនបានឆ្លងកាត់មត្តេយ្យសិក្សារយៈពេល៨សប្តាហ៍
- គោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍកុមារតូច
- ព្រះរាជក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិស្តីពីការគាំពារ និង អភិវឌ្ឍកុមារតូច និងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច
- ប្រកាសស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមត្តេយ្យសាធារណៈ
- សេចក្តីណែនាំស្តីពីដំណើរការគ្រឹះស្ថានបឋមសិក្សា និងមត្តេយ្យសិក្សាសាធារណៈ
- សេចក្តីណែនាំស្តីពីការអនុវត្តន៍មុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ ឃុំសង្កាត់ ក្នុងការអភិវឌ្ឍន៍ផ្នែកសុខភាពមាតាមត្តេយ្យសិក្សា សហគមន៍អានាម័យ សមភាព យេនឌ័រ និងកិច្ចការពារកុមារនៅឃុំសង្កាត់ (សហការជាមួយគ.ជ.អ.ប)
- សេចក្តីព្រាងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យអប់រំ កុមារតូច
- សេចក្តីព្រាងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យអប់រំ កុមារតូច

- សេចក្តីព្រាងគោលការណ៍ និងសេចក្តីណែនាំស្តីពីដំណើរការសាលាមត្តេយ្យសិក្សាធនធានសាលាមត្តេយ្យសិក្សាសហគមន៍ កម្មវិធីអប់រំកុមារតូចតាមផ្ទះ កម្មវិធីអប់រំមាតាបិតាស្តីពីការថែទាំអប់រំលើអាហារូបត្ថម្ភ ការគាំពារ កិច្ចការពារកុមារ ការប្រើប្រាស់សេវាសុខាភិបាលស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ

- ពង្រីកសេវាអប់រំកុមារតូចគ្រប់រូបភាព គ្រប់ទីកន្លែង ជាពិសេសតំបន់ដែលមានអាត្រាចូលរៀនថ្មី និងអត្រាពិតនៃការសិក្សាទាប អាត្រាបោះបង់ការសិក្សាខ្ពស់ និងតំបន់ដែលមានស្ថានភាពអាហារូបត្ថម្ភ ការគាំពារកិច្ចការពារកុមារ និងការប្រើប្រាស់សេវាសុខាភិបាលនៅ ទាប

- ពង្រឹង និងពង្រីកមត្តេយ្យសិក្សាសហគមន៍ពីរភាសា សម្រាប់តំបន់ជនជាតិដើមភាគតិច

- ពង្រីកកម្មវិធីអប់រំបញ្ចូលគ្នា សម្រាប់កុមារមានពិការភាព នៅតាមសាលាមត្តេយ្យសិក្សារដ្ឋនិងមត្តេយ្យសិក្សាសហគមន៍

- ផ្តល់អាហារូបករណ៍ និងលើកកម្ពស់សុខភាពសិក្សាសម្រាប់មត្តេយ្យសិក្សាគ្រប់រូបភាព

- ផ្តល់ឲ្យមាននូវគុណភាព និងគាំទ្របច្ចេកទេសដល់មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហ-គមន៍ និងកម្មវិធីអប់រំតាមផ្ទះស្របតាមស្តង់ដា (ការបំប៉នគ្រូកម្មវិធីសិក្សាកម្មវិធីអប់រំកាយ និងសុខភាពសម្ភារៈបង្រៀន និងរៀនក្នុង និងក្រៅថ្នាក់ទីតាំង)

-អភិវឌ្ឍប្រព័ន្ធបណ្តុះបណ្តាលដល់គ្រូបង្រៀន តាមរយៈ ការរៀបចំស្តង់ដាប្រព័ន្ធបណ្តុះប-ណ្តាលគ្រូបង្រៀន បញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធ ៩បូក២ បណ្តុះបណ្តាលគ្រូបង្រៀនក្របខ័ណ្ឌរដ្ឋ និងឯកជន

- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធ សម្រាប់ការគាំពារ និងអភិវឌ្ឍកុមារតូច

- ពង្រឹងគោលការណ៍អភិបាលកិច្ច ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅក្រោមជាតិ និង ការធ្វើទំនើបកម្មលិខិតបទដ្ឋានគតិយុត្ត។

**ខ.ថ្នាក់បឋមសិក្សា**[22]

គ្រួសារមួយចំនួនធំដែលពុំសូវមានលទ្ធភាព បានបញ្ជូនកូនៗរបស់គាត់ ឲ្យមករៀននៅថ្នាក់បឋមសិក្សាតែម្តង ដោយសារតែគាត់មានគំនិតថា កូនរបស់គាត់នៅក្មេងសេចក្តីពេកក្នុងការបញ្ជូនឲ្យចូលរៀននៅថ្នាក់មត្តេយ្យសិក្សា នឹងដោយសារតែជីវភាពមិនសូវជាធូរធារផងនោះ ដូចនេះនៅពេលដែលកូនៗគាត់មានអាយុ៦ឆ្នាំ ទើបគាត់បញ្ជូនកូនរបស់គាត់ ឲ្យចូលរៀននៅថ្នាក់បឋមសិក្សា

[22]គណៈកម្មាធិការជាតិ អប់រំសម្រាប់ទាំងអស់គ្នា របាយការណ៍ ស្តីពី ការពិនិត្យឡើងវិញការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ជាតិ ឆ្នាំ២០១៥ ទំព័រ ២៦ ចំណុច២.៥.២

(ថ្នាក់ទី១)តែម្តងទៅ ដោយទុករយៈពេលប៉ុន្មានឆ្នាំមុនចូលរៀននៅបឋមសិក្សា ឲ្យនៅផ្ទះដោយមាន ការមើលថែទាំពីពួកលោកវិញ។ ដោយយោងតាមរបាយការណ៍ពីប្រភពដដែលនៅចំណុច ២.៥.២ បានធ្វើការបង្ហាញ ពីសន្ទស្សន៍យុគភាពយេនឌ័រនៃអាត្រាចូលរៀនរបស់កុមារី មានការកើនឡើងពី ០,៨៦ នៅឆ្នាំសិក្សា២០០០-០១ ដល់ ០,៨៩ នៅឆ្នាំសិក្សា២០១២-១៣ មានន័យថាការសិក្សារបស់ កុមារីនៅថ្នាក់ដំបូងមានការកើនឡើង។ ការអប់រំ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍វិស័យ អប់រំ។ ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំប្រឹងប្រែងដោយសហការណ៍ជាមួយគ្រប់ផ្នែកពាក់ ព័ន្ធ ក្នុងនោះមានដៃគូអភិវឌ្ឍសហគមន៍ និងផ្នែកឯកជន។ ផែនការយុទ្ធសាស្ត្រគោលនយោបាយ សកម្មភាពជាច្រើនបានដាក់ចេញ និងអនុវត្តជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ រួមមានផែនការអប់រំ ជាតិសម្រាប់ទាំងអស់គ្នា ២០០៣-១៥ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងសកម្មភាពសំខាន់ៗមួយ ចំនួនដូចខាងក្រោមៈ

- គោលនយោបាយ និងផែនការគោលកម្មវិធីសាលាកុមារមេត្រីអប់រំកម្រិតមូលដ្ឋាន
- ឯកសារគាំទ្រការអនុវត្តន៍កម្មវិធីសាលាកុមារមេត្រី គ្រប់សមាសភាគទាំង ៦ នៅតាមសា-លារៀន
- ការអនុវត្តន៍អំណានថ្នាក់ដំបូង
- ការអនុវត្តន៍កម្មវិធីអាហារូបករណ៍ និងអាហារពេលព្រឹក
- ការអនុវត្តតេស្តឡើងថ្នាក់ចុងឆ្នាំដើមឆ្នាំសិក្សា
- ការអនុវត្តន៍កម្មវិធីជំនួយដើម្បីកែលម្អសាលារៀន
- ការអនុវត្តន៍កម្មវិធីអប់រំកុមារពិការអប់រំពីរភាសា និងកម្មវិធីពន្លឿនការសិក្សា
- ការអនុវត្តកម្មវិធីសិក្សាដោយផ្តោតលើប្រតិទិនសិក្សា និងវិមជ្ឈការកាលវិភាគតាមតំបន់ភូមិសាស្ត្រជាក់ស្តែង
- បង្កើនការប្រមូលកុមារចូលរៀននៅបឋមសិក្សា និងជាពិសេសក្រុមកុមារបាត់បង់ឱកាស (តាមរយៈការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងអាហារូបត្ថម្ភ នៅតាមសាលាបឋមសិក្សា)
- បង្កើនលទ្ធភាពចូលរួមរបស់ផ្នែកឯកជន និងសហគមន៍លើផ្នែកអភិវឌ្ឍវិស័យអប់រំ និងផ្នែកអប់រំកាយ និងកីឡានៅគ្រប់កម្រិតសិក្សា ជាពិសេសគណៈកម្មការ និងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ប្រភេទ

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត តាមរយៈការកាត់បន្ថយសាលាបឋមសិក្សាមិនគ្រប់កម្រិត បង្កើតសាលារៀនថ្មី និងផ្តល់សម្ភាររូបវន្តបន្ថែម
- ផ្តល់ធាតុចូលមានគុណភាព និងគាំទ្របច្ចេកទេសដល់សាលារៀន ស្របតាមស្តង់ដាគ្រូចេញពីសាលាគរុកោសល្យសៀវភៅសិក្សាគោលសម្ភារៈរៀន និងបង្រៀន
- កែលម្អកម្មវិធីសិក្សាសម្រាប់បឋមសិក្សា
- រៀបចំក្របខណ្ឌធានាគុណភាពសាលារៀន ( ព័ត៌មាន ការដឹកនាំគ្រប់គ្រងសម្ភារបរិក្ខាការ បង្រៀន និងរៀនការងារសុខភាពសិក្សាសម្ភារៈរៀន និងបង្រៀនការគ្រប់គ្រងហិរញ្ញវត្ថុការ អប់រំកាយ និងកីឡាការចូលរួមរបស់មាតាបិតានិងសហគមន៍)
- អភិវឌ្ឍប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន តាមរយៈការរៀបចំស្តង់ដាប្រព័ន្ធបណ្តុះបណ្តាល គ្រូបង្រៀន បញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀន តាមប្រព័ន្ធ ៩បូក៣ បណ្តុះបណ្តាលគ្រូ បង្រៀនសម្រាប់ក្របខ័ណ្ឌរដ្ឋ និងឯកជន
- កែលម្អការបំពេញការងារ និងការទទួលខុសត្រូវរបស់សាលារៀនគ្រូបង្រៀន និងសិស្ស តាមរយៈការតាមដាន-វាយតម្លៃលទ្ធផល នៃការសិក្សារបស់សិស្ស និងផ្តល់ការគាំទ្របានទាន់ពេលវេលា
- បង្កើនគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ និងការទទួលខុសត្រូវរបស់គ្រឹះស្ថានសិក្សាក្នុងការប្រើប្រាស់ថវិកា និងការសម្រេចចិត្តលើកម្មវិធីនានា
- ពង្រឹងការគ្រប់គ្រង ការកសាងផែនការ ការអនុវត្តន៍ ការពិនិត្យតាមដាន និងការធ្វើរបាយ-ការណ៍ផ្អែកលើលទ្ធផលស្របតាមគោលការណ៍អភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បង្កើនការប្រើប្រាស់សេវាសុខាភិបាល ដើម្បីលើកកម្ពស់គ្រប់សេវាអប់រំសុខភាពនៅបឋមសិក្សា។

### គ.ថ្នាក់មធ្យមសិក្សា[23]

សន្ទស្សន៍យេនឌ័រនៃការចូលរៀននៅមធ្យមសិក្សាបឋមភូមិ បានកើនឡើងចាប់ពី ០,៥៩ នៅឆ្នាំសិក្សា ២០០០-០១ រហូតដល់ ០,៩៧ នៅឆ្នាំសិក្សា ២០១២-១៣ មានន័យថាការចូលរៀន

[23]គណៈកម្មាធិការជាតិ អប់រំសម្រាប់ទាំងអស់គ្នា របាយការណ៍ ស្តីពី ការពិនិត្យឡើងវិញការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ជាតិ ឆ្នាំ២០១៥ ទំព័រ ៣១ ចំណុច២.៥.៣.៤

របស់ កុមារីកាន់តែមានភាពល្អប្រសើរឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ មូលហេតុដែលធ្វើឲ្យ មានការកើនឡើងនៅចំនួនក្មេងស្រីចូលរៀនច្រើនបែបនេះ ដោយសារតែក្រសួងយុវជន អប់រំ និង កីឡាមានគោលនយោបាយលើកកម្ពស់ការចូលរៀនរបស់កុមារី តាមរយៈការផ្តល់អាហារពេលព្រឹក ការចូលរៀនដោយឥតបង់ថ្លៃសិក្សា ការសាងសង់សាលារៀននៅជិតផ្ទះប្រជាជន និងសាងសង់ បង្គន់អានាម័យសិស្សស្រីដាច់ដោយឡែកពីសិស្សប្រុស។ កំឡុងឆ្នាំ ២០០៩-១៣ សកម្មភាពគោល នយោបាយមួយចំនួនត្រូវបានរៀបចំឡើងមានដូចជា ផែនការគោលស្តីពីការអភិវឌ្ឍន៍មធ្យមសិក្សា និងសៀវភៅប្រតិបត្តិ សម្រាប់ដំណើរការមជ្ឈមណ្ឌលធនធាន សម្រាប់មធ្យមសិក្សា គោលនយោ- បាយស្តីពីសាលាកុមារមេត្រីនៅមធ្យមសិក្សា និងការកែលម្អកម្មវិធីសិក្សា។

ក្រៅពីនោះផងដែរ រាជរដ្ឋាភិបាលក៏មានគោលការណ៍ក្នុងការលើកកម្ពស់យេនឌ័រ តាមរយៈ ការលើកកម្ពស់ និងអនុវត្តច្បាប់គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ដែលលើកកម្ពស់សមភាព យេនឌ័រនៅគ្រប់ទិដ្ឋភាពនៃការរស់នៅ។ លើកទឹកចិត្តដល់សាធារណៈជនវិស័យឯកជន និងសង្គម ស៊ីវិលឲ្យយកចិត្តទុកដាក់ទៅលើបញ្ហាវិសមភាពយេនឌ័រ និងដោះស្រាយនូវបញ្ហាទាំងនោះ។ ជួយ ជម្រុញ និងផ្តល់តួនាទីដឹកនាំ និងសិទ្ធក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដល់យុវតីនៅក្នុងគ្រួសារសហ- គមន៍ និងសង្គម។ ធ្វើការបញ្ជ្រាបយេនឌ័រ និងការវិភាគយ៉ាងលម្អិតអំពីបញ្ហាវិសមភាពយេនឌ័រនៅ ក្នុងគ្រប់ផែនការសកម្មភាពទាំងអស់នៃគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍន៍យុវជន និងបង្កើន ចំណេះដឹងអំពីការងារនេះក្នុងចំណោមយុវជន ជាពិសេសយុវតី តាមរយៈកម្មវិធីអប់រំ និងកម្មវិធី បណ្តុះបណ្តាលនានា។ ជួយលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រនៅក្នុងស្រទាប់យុវជន ដើម្បីជា មូលដ្ឋានដ៏រឹងមាំនៃការគោរពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា និងជាដៃគូរដ៏មានប្រសិទ្ធភាពរវាង បុរស និងស្ត្រីក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយសមភាពសមធម៌ក្នុងការទទួលបាន ផលប្រយោជន៍។

### ឃ.ថ្នាក់មធ្យមសិក្សាទុតិយភូមិ[24]

ដើម្បីធ្វើឲ្យព្រះរាជាណាចក្រកម្ពុជា មានធនធានមនុស្សសម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិ រាជរដ្ឋាភិបាលមានចក្ខុវិស័យរយៈពេលវែង ដោយប្រមូលកម្លាំងពីគ្រប់មជ្ឈដ្ឋាននៅក្នុងសង្គមជាតិ សំដៅរួមចំណែកអភិវឌ្ឍយុវជន ឲ្យកាន់តែមានលក្ខណសម្បត្តិជាវិជ្ជមាន និងផ្តល់ឱកាសឲ្យពួកគេ

[24]គណៈកម្មាធិការជាតិ អប់រំសម្រាប់ទាំងអស់គ្នា របាយការណ៍ ស្តីពី ការពិនិត្យឡើងវិញការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ជាតិ ឆ្នាំ២០១៥ ទំព័រ ២៩ ចំណុច២.៥.៣.៣

អភិវឌ្ឍសក្តានុពលនៅក្នុងការអប់រំការងារសុខភាពការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងការចូលរួម ចំណែកអភិវឌ្ឍគ្រួសារសហគមន៍ប្រទេសជាតិ និងពិភពលោក។ ការលើកកម្ពស់ការអប់រំការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍សមត្ថភាពរបស់រាជរដ្ឋាភិបាល និងគ្រប់អង្គភាពដែលពាក់ព័ន្ធត្រូវធ្វើការជម្រុញ និងលើកទឹកចិត្តដល់យុវជនឲ្យទទួលបាននូវការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈសម ស្របជាពិសេសយុវជនដែលពុំសូវមានឱកាស និងយុវជនដែលងាយរងគ្រោះ ក្នុងមាននោះយុវជនពិការជាដើម។ ធ្វើការជម្រុញកម្មវិធីបំណិនជីវិតដែលឆ្លើយតបទៅនឹងតម្រូវការជីវភាពរស់នៅរបស់យុវជន និងទីផ្សារពលកម្ម។ ចូលរួមលើកកម្ពស់គុណភាពអប់រំបច្ចេកវិទ្យាវិទ្យាសាស្ត្រ និងភាសាបរទេសនៅគ្រប់ភូមិសិក្សានៃប្រព័ន្ធអប់រំកម្ពុជា ឲ្យស្របតាមតម្រូវការរបស់សង្គមជាតិ និងស្រប តាមស្តង់ដាតំបន់ និងអន្តរជាតិ។ បង្កឱកាសដល់យុវជនកម្ពុជាទាំងអស់ ជាពិសេសគឺស្ត្រីឲ្យទទួលបាន និងបញ្ចប់ការសិក្សាយ៉ាងហោចណាស់ត្រឹមការអប់រំកម្រិតមូលដ្ឋាន និងបង្កើនអាត្រាគង់វង្ស នៅគ្រប់ភូមិសិក្សានៃប្រព័ន្ធអប់រំ។ អភិវឌ្ឍមជ្ឈមណ្ឌលយុវជន និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងជម្រុញលើកទឹកចិត្តយុវជនឲ្យចូលរួមយ៉ាងសកម្មក្នុងការសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមសហគមន៍។

យើងបានឃើញពីភាពរីកឡើងនូវសន្ទុះចូលរៀនរបស់កុមារី តាមរយៈសន្ទស្សន៍យុគភាពយេនឌ័រនៃការចូលរៀននៅមធ្យមសិក្សាទុតិយភូមិបានកើតពី ០,៩៧ នៅឆ្នាំសិក្សា ២០០០-០១ ដល់ ០,៨៧ នៅឆ្នាំសិក្សា ២០១២-១៣ មានន័យថាការចូលរៀនរបស់កុមារីមានភាពកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

### ខ.ថ្នាក់ឧត្តមសិក្សា[25]

អគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សា បានអភិវឌ្ឍសមត្ថភាពរបស់ខ្លួនក្នុងការងារកសាងផែនការ និងពិនិត្យតាមដាន ការគ្រប់គ្រងមូលនិធិស្រាវជ្រាវ និងអាហារូបករណ៍ និងមានលទ្ធភាពទាញយកមូលនិធិកាន់តែច្រើនដើម្បីធ្វើការពង្រីកកម្មវិធី។ គណៈកម្មការទទួលស្គាល់គុណភាពអប់រំកម្ពុជាមានសមត្ថភាពខ្ពស់ក្នុងការគ្រប់គ្រង និងដំណើរការប្រព័ន្ធទទួលស្គាល់គុណភាព។ វប្បធម៌នៃការស្រាវជ្រាវបានចាប់ផ្តើមផុសឡើងតាមរយៈការអនុវត្តកម្មវិធីផ្តល់មូលនិធិស្រាវជ្រាវ និងមានកិច្ចសហប្រតិបត្តិការក្នុងតំបន់រឹងមាំ កិច្ចសហការ និងសកម្មភាពបានអនុវត្តរួមគ្នា។ សកម្មភាពគោលនយោបាយសំខាន់ៗមួយចំនួនដែលត្រូវបានអនុវត្តដូចជា ការអនុម័តផែនការណ៍

[25]គណៈកម្មាធិការជាតិ អប់រំសម្រាប់ទាំងអស់គ្នា របាយការណ៍ ស្តីពី ការពិនិត្យឡើងវិញការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ជាតិ ឆ្នាំ២០១៥ ទំព័រ ៣៨ ចំណុច២.៥.៦

គោលស្តីពី ការស្រាវជ្រាវព្រះរាជក្រឹត្យ ស្តីពីចំណាត់ថ្នាក់សាស្ត្រាចារ្យ និងការរៀបចំទស្សនៈវិស័យឆ្នាំ២០៣០។ ការបង្កើតក្រុមការងារបច្ចេកទេសឧត្តមសិក្សា ជាដំណាក់កាលសំខាន់មួយ ក្នុងការបង្កើតវេទិកាមួយសម្រាប់ការជជែក និងពិភាក្សាអំពីបញ្ហានៅកម្រិតឧត្តមសិក្សា ។

បញ្ហាប្រឈមចម្បងសម្រាប់ឆ្នាំខាងមុខនេះគឺ ការដោះស្រាយពីភាពខុសគ្នារវាងតម្រូវការទីផ្សារការងារជាពិសេសជំនាញសមត្ថភាពក្នុងការគិតពិចារណាចំណេះដឹង ជាមួយនិងទីផ្សារការងារនាពេលបច្ចុប្បន្ន។ កត្តានេះទាមទារឲ្យមានការយល់ដឹងកាន់តែប្រសើរឡើងអំពីទីផ្សារ ការងារ ការសម្របសម្រួលល្អប្រសើរជាងមុន និងមានតំណភ្ជាប់ជាមួយនឹងវិស័យឧស្សាហកម្ម និងព័ត៌មានកាន់តែប្រសើរឡើងសម្រាប់និស្សិត ដូច្នេះពួកគេអាចជ្រើសរើសវគ្គសិក្សាដែលសមស្រប។ ដើម្បីរក្សាបាននូវកម្មវិធីដែលមានគុណភាពខ្ពស់ដែលអាចទទួលស្គាល់ជាអន្តរជាតិ ការកំណត់តម្លៃមួយដែលមានកម្រិតសមរម្យ ក៏ជាបញ្ហាប្រឈមមួយផងដែរ។ ការបង្កើនកិច្ចខិតខំប្រឹងប្រែង និងការផ្តល់ធនធានបន្ថែមជាកត្តាចាំបាច់ ដើម្បីធានាថាសិស្សដែលមានទេពកោសល្យ និងមកពីក្រុមជួបការលំបាកនឹងអាចចូលសិក្សានៅថ្នាក់ឧត្តមសិក្សាតាមរយៈកម្មវិធីអាហារូបករណ៍ ឬគម្រោងប្រាក់ កម្ចីសម្រាប់ការសិក្សា។

រាជរដ្ឋាភិបាល បានទទួលស្គាល់អំពីសារៈសំខាន់ នៃការផ្តល់ឱកាសក្នុងការសិក្សានៅថ្នាក់ឧត្តមសិក្សា និងអំពីសារៈសំខាន់ក្នុងការធានាគុណភាព និងភាពឆ្លើយតប ។ ការធ្វើសមាហរណកម្មអាស៊ាននឹងផ្តល់ជាឱកាសសម្រាប់ការសហការរវាងស្ថាប័ន ការស្រាវជ្រាវរួមគ្នា និងការកំណត់ស្តង់ដាគុណភាព។

ពីឆ្នាំសិក្សា ២០០០-០១ ដល់ឆ្នាំសិក្សា ២០១២-១៣ និស្សិតឧត្តមសិក្សានៅគ្រឹះស្ថានសិក្សាសាធារណៈកើនពី ២៦.៣៦១នាក់ ទៅ ៩៦.៤៦០នាក់ ក្នុងនោះនិស្សិតស្រីកើនពី ៥.៥៣៨នាក់ ទៅ ៣៧.៤៤៤នាក់ មានន័យថាសន្ទុះនិស្សិតស្រីនៅឧត្តមសិក្សាកំពុងតែកើនឡើងជាបណ្តើរៗពីមួយឆ្នាំ ទៅមួយឆ្នាំ។

### ១.១.២ ការអប់រំនៅក្នុងគ្រឹះស្ថានឯកជន[26]

នៅចំណុចនេះ ដោយសារតែមានការខ្វះខាតឯកសារ ដូច្នេះក្រុមយើងខ្ញុំអាចធ្វើការបង្ហាញត្រឹមតែមួយផ្នែកសិក្សានៅកម្រិតថ្នាក់បរិញ្ញាបត្រនៅគ្រឹះស្ថានសិក្សាឯកជនតែប៉ុណ្ណោះ។ យើងបានរកឃើញថា នៅចន្លោះឆ្នាំសិក្សា ២០០០-០១ មានចំនួនសិស្សសរុបដែលធ្វើការសិក្សានៅ

[26]គណៈកម្មាធិការជាតិ អប់រំសម្រាប់ទាំងអស់គ្នា របាយការណ៍ ស្តីពី ការពិនិត្យឡើងវិញការអប់រំសម្រាប់ទាំងអស់គ្នា ថ្នាក់ជាតិ ឆ្នាំ២០១៥ ទំព័រ ៣៩ ចំណុច២.៥.៦.២

គ្រឹះស្ថាន ឯកជន មានចំនួនប្រមាណជា ៥.៥៧៩នាក់ ដែលក្នុងនោះសិស្សស្រីមានចំនួន ១.៣១៣ នាក់ រហូតមកដល់ឆ្នាំ ២០១២-១៣ យើងឃើញពីសន្ទុះប្រែប្រួលនៅចំនួនសិស្សចូលរៀននៅគ្រឹះស្ថានឯកជន គួរឲ្យកត់សម្គាល់ គឺមានចំនួនសិស្សសរុបដល់ទៅ ១១៩.៥៩៣នាក់ ដែលរួមមានចំនួនសិស្សស្រី ៤៨.៧៩១នាក់។ នេះគឺជាសន្ទុះមួយដែលមានការកើនឡើងយ៉ាងច្រើនសម្រាប់ស្ត្រីក្នុងវិស័យអប់រំ។ គឺជាតួរលេខមួយដែលអាចឲ្យយើងបានដឹងថា មានស្ត្រីជាច្រើនបាននឹងកំពុងតែព្យាយាមស្វែងរក ឱកាសសិក្សាយ៉ាងច្រើនដូចជាបុរសដែរ។

### ១.២ តាមបណ្តាលខេត្តមួយចំនួន

ការរីកចម្រើនយ៉ាងឆាប់រហ័សឥតឈប់ឈរ និងការប្រកួតប្រជែងស្វែងរកឧត្តមភាពនៅលើពិភពលោកក្នុងបរិបទសកលភាវូបនីយកម្ម ទាមទារឲ្យប្រទេសនីមួយៗខិតខំបង្កើនគុណភាពផលិតផល និងសេវាកម្មរបស់ខ្លួនឲ្យបានជាអតិបរមា។ ការប្រើប្រាស់ធនធានមនុស្សឲ្យអស់ពីលទ្ធភាព មានសារៈសំខាន់ណាស់ ដែលជាកម្លាំងចលករមិនអាចខ្វះបានក្នុងការធ្វើឲ្យសម្រេចបំណងប្រាថ្នាខាងលើ និងអាចធ្វើឲ្យអាជីពជីវិតបុគ្គលអង្គភាពសង្គម និងប្រទេសជាតិមានការផ្លាស់ប្តូរនឹងរីក ចម្រើនប្រកបដោយចីរភាព។

សមាហរណកម្មទៅក្នុងតំបន់ តម្រូវឲ្យកម្ពុជាចូលរួមក្នុងកិច្ចសហការ និងប្រកួតប្រជែងជាមួយប្រទេសជិតខាងលើគ្រប់វិស័យ ដើម្បីសម្រេចបានចក្ខុវិស័យរួមរបស់អាស៊ាន។ ដើម្បីអាចសម្របខ្លួនទៅនឹងការវិវត្តរបស់ពិភពលោក និងតំបន់ក្នុងន័យបង្កើនភាពឆ្លើយតប និងការប្រកួតប្រជែងកម្ពុជាត្រូវតែមានធនធានមនុស្សដែលមានសមត្ថភាព និងវិជ្ជាជីវៈខ្ពស់។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សដូចមានចែងក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន។ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលបាននឹងកំពុងរៀបចំធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ សំដៅបង្កើនសមត្ថភាពប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិសេវាសាធារណៈ ឲ្យឆ្លើយតបទៅនឹងបរិបទខាងលើឲ្យទាន់ពេលវេលា។ ទាំងនេះ ស្តែងចេញតាមរយៈការកសាងលិខិតបទដ្ឋានគតិយុត្តជាច្រើន ទាក់ទងនឹងលក្ខន្តិកៈក្រប-ខណ្ឌ ជំរឿន ទិន្នន័យប្រព័ន្ធចំណាត់ថ្នាក់ ប្រព័ន្ធលាភការ និងសនិទានកម្មមន្ត្រីរាជការស៊ីវិល។

ក្រសួងអប់រំ យុវជន និងកីឡា ជាក្រសួងអាទិភាពមួយរបស់រាជរដ្ឋាភិបាលដែលមានចំនួនបុគ្គលិកបម្រើការច្រើនជាងគេ។ ប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងក្រសួងអប់រំ យុវជន និងកីឡា មានសារៈសំខាន់ណាស់ព្រោះមិនត្រឹមតែជួយធ្វើឲ្យគោលនយោបាយកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលអាចអនុវត្តបានដោយល្អប្រសើរ និងមានចីរភាព ជាពិសេសការ

ប្រើប្រាស់ធនធានមនុស្សក្នុងមុខងារសាធារណៈ។ ដើម្បីដោះស្រាយបញ្ហាប្រឈមមួយចំនួន ដូចជាគុណវុឌ្ឍិ សមត្ថភាព វិជ្ជាជីវៈ ការពង្រាយបុគ្គលិកអប់រំទៅតំបន់ដាច់ស្រយាល ជីវភាពរស់នៅរបស់ បុគ្គលិកអប់រំ លក្ខខណ្ឌបំពេញការងារ ការគ្រប់គ្រងធនធានមនុស្ស ការជ្រើសរើស និងការតែង តាំងគុណភាពបំពេញការងារ និងការគាំទ្រការបង្រៀនក្រសួងអប់រំ យុវជន និងកីឡា បានកសាងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនដូចជា ច្បាប់ស្តីពីការអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ការកសាងគោលនយោបាយស្តីពី ធនធានមនុស្សក្នុងវិស័យអប់រំជាគន្លឹះចាំបាច់ក្នុងការពង្រឹង និងធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានមនុស្សសំដៅបង្កើនគុណភាពប្រសិទ្ធភាពភាពស័ក្តិសិទ្ធិជំនឿទុកចិត្ត និងឆ្លើយតបទាន់ពេលវេលានឹងតម្រូវការផ្តល់សេវាអប់រំដល់បុគ្គល និងគ្រប់អង្គភាពអប់រំស្របតាមស្តង់ដាជាតិតំបន់ និងអន្តរជាតិ។

យើងបានដឹងថាប្រទេសកម្ពុជាមានខេត្ត និងក្រុងសរុបទាំងអស់ចំនួន ២៥ដែលមានភាពរីកចម្រើនខុសប្លែកពីគ្នាទៅតាមតំបន់ដែលបាន និងកំពុងតែអភិវឌ្ឍ។ ខាងក្រោមនេះ យើងនឹងធ្វើការ តាមដានទៅលើការវិវត្តន៍នៃភាពជឿនលឿនផ្នែកវិស័យអប់រំ ជាពិសេសកំណើនស្ត្រីដែលបានចូល រៀនតាមកម្រិតថ្នាក់នៅខេត្តចំនួនពីរ ដែលយើងធ្វើការជ្រើសរើសយកមកប្រៀបធៀប ក្នុងចន្លោះប៉ុន្មានឆ្នាំចុងក្រោយនេះ ពីការចូលរៀនរបស់ពលរដ្ឋគ្រប់រូប ជាពិសេសគឺស្ត្រីដែលបានចូលរៀន។

### ១.២.១ នៅទីរួមខេត្ត[27]

ត្រង់ចំណុចពាក្យថា ***ទីរួមខេត្ត*** ដែលក្រុមយើងខ្ញុំលើកយកមកនេះ គឺមានន័យថា ជាខេត្តដែលមានសេដ្ឋកិច្ចជឿនលឿន មានមនុស្សរស់នៅច្រើនកកកុញមានការអភិវឌ្ឍន៍គួរឲ្យកត់សម្គាល់នូវដំណើរការផ្សេងៗមិនចាញ់ពីភាពជឿនលឿន និងការអភិវឌ្ឍន៍នៅទីក្រុងប៉ុន្មានទេ។ យើងនឹងមើលលើភាពខុសប្លែកពីចំនួនសាលារៀន ក៏ដូចជាចំនួនសិស្សស្រីដែលបានចូលរៀនពីមួយឆ្នាំទៅមួយឆ្នាំមានការប្រែប្រួលយ៉ាងណាខ្លះ យើងនឹងពិនិត្យទៅលើស្ថិតិ និងអាំងឌីកាទ័រអប់រំ ដែលបានរៀបចំឡើងសម្រាប់ធ្វើការវង្វាស់ពីការប្រតិបត្តិទៅតាមគោលការណ៍របស់រាជរដ្ឋាភិបាល ថាតើមានភាពប្រសើរឡើង និងត្រូវកែប្រែយ៉ាងណាដើម្បីឲ្យការអប់រំនៅក្នុងប្រទេសកម្ពុជាកាន់តែមានភាពល្អ ប្រសើរដូចបណ្តាលប្រទេសជិតខាងបាន។

នៅក្នុងប្រទេសកម្ពុជាមានសាលារៀនសរុបទាំងអស់ចំនួន ១១.៣៧០ ក្នុងឆ្នាំ២០១២-១៣។ នៅក្នុងនោះ សាលារៀននៅទីក្រុងមានចំនួន១.៣៣៣ និងនៅជនបទមានចំនួន១០.០៣៧។

[27] ស្ថិតិ និងសូចនាករអប់រំ ឆ្នាំ២០១១-២០១២ និង២០១២-២០១៣ ទំព័រ ១ និង ២

ដោយសារតែចំណុចនេះយើងធ្វើការបង្ហាញពីទីរួមខេត្ត ដូច្នេះយើងនឹងបង្ហាញពីខេត្តមួយក្នុងចំណោមខេត្តផ្សេងៗទៀតដែលមាននៅក្នុងប្រទេសកម្ពុជា មកបញ្ជាក់ពីទិន្នន័យនៃការកើនឡើង ឬធ្លាក់ចុះនៃ ចំនួនសាលារៀន បន្ទប់សិក្សា ចំនួនសិស្សសរុប និងចំនួនសិស្សស្រី។ ទិន្នន័យទាំងនេះនឹងធ្វើការ ប្រៀបធៀបរវាងឆ្នាំ ២០១១-១២ និង ២០១២-១៣។

ខេត្តកំពង់ចាម គឺជាខេត្តមួយដែលប្រជាជនភាគច្រើនប្រកបរបរចិញ្ចឹមជីវិត ដោយការបើកអាជីវកម្មនៅផ្ទះ តាមផ្សារ ជាកសិករ និងមានមួយចំនួនទៀតបានធ្វើបរដាំដុះនូវដំណាំផ្សេងៗ ជាពិសេសគឺការដាំចម្ការកៅស៊ូ។ យ៉ាងណាមិញក៏ប្រជាជននៅតំបន់នេះ បានបញ្ជូនកូនប្រុសស្រីរបស់ ខ្លួនឲ្យទៅសិក្សានៅសាលារៀនដែរ។ តាមទិន្នន័យដែលយើងទទួលបាន នៅចន្លោះឆ្នាំ ២០១១-១២ សាលារៀនសរុបមានចំនួន ១.២៧២ ក្នុងនោះថ្នាក់រៀន មានចំនួន ៩.៦៧៣ ហើយសិស្សសរុបមាន ចំនួន ៣៩២.៥១២ ចំណែកសិស្សស្រីដែលបានចូលរៀនវិញមានចំនួនសរុបទាំងអស់ ១៨៩.៤០៦។ យើងបានដឹងថា តួលេខទាំងនេះត្រូវ បានកើនឡើងនៅក្នុងឆ្នាំ ២០១២-១៣។ ចំនួនសាលាបាន កើនដល់ ១.២៨៦ បន្ទប់សិក្សាកើនដល់ ៩.៧០១ សិស្សសរុបចំនួន ៣៩៤.៥៩៩ រីឯសិស្សស្រីវិញ បានកើនដល់ ១៩០.៣៩៧។ យើងបានឃើញថាចំនួនសិស្សស្រីបានកើនរហូតដល់ទៅ ៩៩១នាក់ សម្រាប់ខេត្តមួយនេះនៅក្នុងចន្លោះត្រឹមតែមួយឆ្នាំតែប៉ុណ្ណោះ។

### ១.២.២ ទីដាច់ស្រយាល[28]

***ទីដាច់ស្រយាល*** គឺជាតំបន់មួយ ដែលពុំសូវមានប្រជាជនរស់នៅច្រើននឹងពុំមានភាពសម្បូរបែបដូចជាទីក្រុង ឬទីរួមខេត្តប៉ុន្មាននោះទេ។ ដោយសារតែតំបន់នេះនៅឆ្ងាយពីទីប្រជុំជន និងមានភាពកង្វះខាតជាច្រើន ក្នុងនោះមានដូចជាចំណីអាហារ អគ្គិសនី ទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងតំបន់។ ខាងក្រោមនេះ យើងនឹងពិនិត្យទៅលើខេត្តមណ្ឌលគិរី ដែលត្រូវបានគេចាត់ជាតំបន់ដាច់ស្រយាលក្នុងចំណោមខេត្តប្រាំមួយផ្សេងទៀត។ ដោយយោងទៅតាមស្ថិតិ និងអាំងឌីកាទ័រ បានឲ្យយើងដឹងថាក្នុងឆ្នាំ ២០១១-១២ សាលារៀនដែលមាននៅទីនោះ មានចំនួន ១០៥ ដែលមានបន្ទប់រៀនចំនួន៥៦៩ សិស្សប្រុសស្រីសរុបចំនួន១៤.៩២៦ និងសិស្សស្រីចំនួន៧.១៣១។ ហើយនៅក្នុងឆ្នាំ២០១២-១៣ សាលារៀនសរុបមានចំនួន ១១១ បន្ទប់រៀនមាន ៥៩៧ សិស្សសរុប ១៦.០៤៩ និង សិស្សស្រីមាន ៧.៥៤២។ បើធៀបទៅនឹងឆ្នាំចាស់យើងបានដឹងថា សិស្សស្រីមានការកើនឡើង បាន ៥១១នាក់។ នេះជាអ្វីដែលយើងគួរមានមោទនភាព ដោយសារតែខេត្តនេះស្ថិតនៅក្នុងតំបន់ ដាច់ស្រយាលពីគេបន្តិចក៏ដោយ ក៏ប្រជាពលរដ្ឋនៅទីនោះ នៅតែបញ្ជូនកូនស្រី

[28]ស្ថិតិ និងសូចនាករអប់រំ ឆ្នាំ២០១១-២០១២ និង២០១២-២០១៣ ទំព័រ ១ និង ២

ប្រុសរបស់គាត់ឲ្យ បានទៅក្រេបយកចំណេះដឹងពីលោកគ្រូអ្នកគ្រូនៅសាលារៀនដែរ។ ម្យ៉ាងដោយសារតែការគិតគូរ ជិតដល់របស់រាជរដ្ឋាភិបាលទៅលើវិស័យអប់រំ ដូច្នេះទើបបានជាមានការបង្កើតឲ្យមានសាលារៀន នៅតំបន់ដាច់ស្រយាលជាបន្តបន្ទាប់ ទៅតាមលទ្ធភាពដែលរាជរដ្ឋាភិបាលមាន និងព្យាយាមស្វែង រកជំនួយតាមមធ្យោបាយផ្សេងៗ ដើម្បីបង្កើតសាលារៀន ក៏ដូចជាព្យាយាមបណ្តុះបណ្តាលសមត្ថភាពលោកគ្រូអ្នកគ្រូតាមតំបន់ខ្វះខាត ដើម្បីឲ្យប្រជាពលរដ្ឋអាចបញ្ជូនកូនៗរបស់គាត់ទៅសាលា រៀនបាន។

## ផ្នែកទី ២៖ ការអភិវឌ្ឍន៍ និងឧបសគ្គនាពេលបច្ចុប្បន្ន[29]

ដើម្បីធានាសង្គតិភាពនៃឋានានុក្រម តួនាទី ខ្លឹមសារ និងលំដាប់លំដោយនៃការអនុវត្តរវាងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ ជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នក្នុងឆ្នាំ២០០៩-១៣ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-១៣ត្រូវបានពិនិត្យឡើងវិញសំដៅកែលម្អសេវាអប់រំឲ្យកាន់តែប្រសើរថែមទៀត។

ការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-១៣នេះ បានបង្ហាញអំពីបម្រែបម្រួល និងបង្ហាញពីដំណាក់កាលការងារដ៏សំខាន់មួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡានៅកម្ពុជា ស្របតាមកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល។ ក្នុងរយៈពេល៥ឆ្នាំ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំកន្លងមកនេះក្រសួងនិងដៃគូអភិវឌ្ឍ បានធ្វើឲ្យមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ក្នុងការផ្តល់ការអប់រំប្រកបដោយសមធម៌ ការកែលម្អគុណភាព និងប្រសិទ្ធភាពសេវាអប់រំ និងការគ្រប់គ្រងសេវាអប់រំ ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-១៣ ត្រូវបានរៀបរៀងឡើងដើម្បីផ្សារភ្ជាប់ទំនាក់ទំនងរវាងគោលនយោបាយ និងយុទ្ធសាស្ត្រអប់រំជាមួយនឹងកម្មវិធី និងសកម្មភាពអភិវឌ្ឍនានាព្រមទាំងការផ្សាភ្ជាប់ផែនការទៅនឹងថវិកា។ នៅក្នុងដំណាក់កាលនេះ ក្រសួងនៅតែបន្តផ្តល់អាទិភាពខ្ពស់លើការចូលរៀនប្រកបដោយសមធម៌ និងមានគុណភាពខ្ពស់ ជាពិសេសការអប់រំកម្រិតមូលដ្ឋាន ដែលនឹងឈានទៅសម្រេចផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នានៅឆ្នាំ២០១៥។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-១៣ ក៏បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ផងដែរ លើការអប់រំកុមារតូច ការពង្រីកការងារអប់រំក្រៅប្រព័ន្ធ ការអប់រំបច្ចេកទេសវិជ្ជាជីវៈ ការពង្រីកឱកាសទទួលសេវាអប់រំមធ្យមសិក្សា និងក្រោយមធ្យមសិក្សា តាមរយៈបន្តអនុវត្តគោលការណ៍និងភាពជាដៃគូឲ្យបានកាន់តែប្រសើររវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល និង

[29] ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣

សហាគមន៍ មាតាបិតាសិស្ស។ លើសពីនេះទៀតត្រូវធានាថា ការចំណាយលើវិស័យអប់រំពិតជាទទួលបានផលប៉ះពាល់ជាអតិបរមា ជាពិសេស ផ្ដោតការយកចិត្តទុកដាក់ទៅលើការអប់រំសម្រាប់កុមារ និងយុវជនបាត់បង់ឱកាស តាមរយៈការរៀបចំឲ្យមានវិធានការច្បាស់លាស់ ដែលធានាដល់ប្រសិទ្ធភាពនៃការចំណាយថវិកាអប់រំ។ ការពង្រឹងការអនុវត្តច្បាប់ស្ដីពីការអប់រំក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងអភិបាលកិច្ចល្អ ក៏ជាកិច្ចការមួយដែលត្រូវយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លា។ ស្របពេលជាមួយគ្នានេះដែរការលើកទឹកចិត្ត និងការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកអប់រំ នៅគ្រប់កម្រិតសម្រាប់អនុវត្តវិមជ្ឈការអប់រំ ក៏ជាសមាសភាគដ៏សំខាន់ផងដែរ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-១៣ ត្រូវបានរៀបចំឡើងដោយមានយន្តការ ការងារច្បាស់លាស់ ការសិក្សា ការពិគ្រោះយោបល់ ក៏ដូចជាការចូលរួមបានទូលំទូលាយពីសំណាក់អ្នកពាក់ព័ន្ធនានា ពិសេសក្រុមការងារវិស័យអប់រំ។ ក្រសួងសង្ឃឹមយ៉ាងមុតមាំថា ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-១៣ នឹងកំណត់ផែនទីចង្អុល សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធិភាពសំដៅជម្រុញវិស័យអប់រំឲ្យលឿនទៅមុខ ដើម្បីជាគុណប្រយោជន៍ដល់ពលរដ្ឋកម្ពុជាគ្រប់រូប។

## ២.១ ការអភិវឌ្ឍន៍[30]

ប្រទេសកម្ពុជាបានចាត់ទុកថា ការវិនិយោគលើមូលធនមនុស្សជាពិសេសស្ត្រីនៅក្នុងវិស័យអប់រំ ជាឧបករណ៍ដ៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ ការអប់រំដើរតួនាទីយ៉ាងសំខាន់ ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយសីលធម៌ ចំណេះ-ដឹង បញ្ញា មនោគមវិជ្ជា វប្បធម៌ សង្គម វិទ្យាសាស្ត្រ និងការអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យា ព្រមទាំងគោលដៅឯកភាពជាតិ ប្រជាធិបតេយ្យ ការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ច និងសន្តិសុខសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងមូល។

ទិន្នន័យអប់រំសម្រាប់ស្ត្រី ដែលមានលក្ខណៈពិតប្រាកដ និងទាន់ពេលវេលាគឺមានសារៈសំខាន់ណាស់ សម្រាប់ធ្វើផែនការអប់រំ ការពិនិត្យតាមដាន ការវាយតម្លៃ និងការរៀបចំថវិកាឲ្យមានប្រសិទ្ធភាព និងសម្រាប់ការងារដទៃៗទៀត ដែលមានអត្ថប្រយោជន៍ដល់កិច្ចដំណើរការ និងវឌ្ឍនភាពរបស់ប្រព័ន្ធអប់រំនៅតាមកម្រិតនីមួយៗរបស់រាជរដ្ឋាភិបាល។ ព័ត៌មានដែលពាក់ព័ន្ធទៅនឹងសូចនាករអប់រំ គឺចាំបាច់ត្រូវមានការវាស់វែងអំពីវឌ្ឍនភាព ធៀបទៅនឹងគោលដៅសំខាន់ៗសម្រាប់ប្រព័ន្ធអប់រំរបស់យើង ដូចជាគោលដៅអភិវឌ្ឍសហស្សវត្សឆ្នាំ២០១៥ និងចំណុចដៅអប់រំសម្រាប់ទាំងអស់គ្នា។

[30] ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ និងគោលនយោបាយស្តីពី បច្ចេកវិទ្យាពត៌មាន និងសារគមនាគមន៍ក្នុងការអប់រំ ឆ្នាំ ២០០៩-២០១៣

វឌ្ឍនភាពឈានឆ្ពោះទៅរកគោលដៅសម្រេចឲ្យបាននូវព័ត៌មានពិតប្រាកដ និងទាន់ពេលវេលា យើងចាំបាច់ត្រូវមានផែនការគោលប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំឆ្នាំ ២០១៤-២០១៨ ។ ផែនការនេះ ត្រូវបានរៀបចំឡើងដើម្បីធានាថា ការរៀបចំផែនការអប់រំរបស់កម្ពុជានឹងត្រូវផ្តល់ដោយទិន្ន ន័យពិតប្រាកដ គ្រប់គ្រាន់ និងទាន់ពេលវេលា។ ផែនការគោលនេះបានផ្តល់នូវផែនទីចង្អុលផ្លូវដ៏ទូលំទូលាយ ដើម្បីកែលម្អទិន្នន័យអប់រំគ្រប់ប្រភេទ លើការពិនិត្យតាមដាន និងការធ្វើផែនការនៅតាមផ្នែកមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងឧត្តមសិក្សានៅប្រទេសកម្ពុជា។

ផែនការគោលនេះ ផ្សាភ្ជាប់ទៅនឹងចក្ខុវិស័យជាតិ តាមបែបប្រជាធិបតេយ្យដោយមានការចូលរួម ដែលក្នុងនោះប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលទទួលបាននូវព័ត៌មានពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំដែលអាចដើរតួនាទីយ៉ាងសកម្ម ក្នុងការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច។ ផែនការគោលប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំនឹងគាំទ្រវត្ថុបំណង នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-១៨ និងគោលនយោបាយស្តីពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងការអប់រំឆ្នាំ២០០៩-១៣។ ផែនការគោលទាំងនោះមានចំណុចសំខាន់ដូចជា ៖

- ពង្រឹងសមត្ថភាព និងប្រព័ន្ធសម្រាប់ការវិភាគ ការធ្វើផែនការ ការពិនិត្យតាមដាន ការពិនិត្យឡើងវិញ និងការវាយតម្លៃនៅគ្រប់កម្រិត
- ពង្រឹងសមត្ថភាព និងប្រព័ន្ធ ដើម្បីគ្រប់គ្រងអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងសមធម៌
- គ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ គ្រប់គ្រងព័ត៌មាននិងគ្រប់គ្រងរដ្ឋបាលប្រកបដោយប្រសិទ្ធភាពនិងពង្រឹងសមត្ថភាព និងប្រព័ន្ធសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុនិងសវនកម្ម។

យើងសង្ឃឹមថា តាមរយៈការអនុវត្តផែនការគោលនេះ ការធ្វើផែនការអប់រំសម្រាប់ស្ត្រីនៅគ្រប់កម្រិត នឹងត្រូវបានពង្រឹងនៅតាមបណ្តាឆ្នាំខាងមុខ។ ផែនការនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ស្ត្រីគ្រប់រូបតាមរយៈការលើកឡើងពីបញ្ហាវិសមភាពនានា និងការកែលម្អការចូលរៀន ដើម្បីទទួលបានការអប់រំ ប្រកបដោយគុណភាព។ ក្រសួងសង្ឃឹមយ៉ាងមុតមាំថា គ្រប់ភាគីពាក់ព័ន្ធទាំងអស់នឹងចូលរួមគាំទ្រដល់ការអនុវត្តផែនការគោលប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ២០១៤-១៨ ឲ្យទទួលបានជោគជ័យ ។

### ២.១.១ បរិបទគោលនយោបាយ[31]

ព្រះរាជាណាចក្រកម្ពុជា បានបង្កើតឲ្យមានក្របខណ្ឌច្បាប់ និងគោលនយោបាយសម្រាប់ការបញ្ជ្រាបយេនឌ័រ ក្នុងវិស័យអប់រំ ប្រកបដោយភាពជោគជ័យ និងមានរចនាសម្ព័ន្ធស្ថាប័នដ៏រឹងមាំសម្រាប់ការបញ្ជ្រាបយេនឌ័រនៅថ្នាក់ជាតិ។

ធនធានមនុស្សនៃក្រសួងអប់រំ យុវជន និងកីឡា នៅថ្នាក់ជាតិ ទាក់ទងនឹងសមភាពយេនឌ័រ មានការរីកចម្រើនគួរជាទីកត់សម្គាល់។ ឆ្លើយតបទៅនឹងផែនការអប់រំសម្រាប់ទាំងអស់គ្នា (EFA) របស់ក្រសួងអប់រំ យុវជន និងកីឡា ចាប់តាំងពីឆ្នាំ ២០០៨មក បានស្តែងឲ្យឃើញនូវកិច្ចប្រឹងប្រែង និងលទ្ធផលល្អគួរជាទីពេញចិត្ត និងជាពិសេសលើការកែលម្អគុណភាពនៃការអបប់រំ តាមរយៈការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យអប់រំ។

លទ្ធផលទាំងនេះ សម្រេចបានតាមរយៈការកសាងសមត្ថភាពស្ថាប័នក្នុងការកែលម្អគុណ-ភាពនៃការអប់រំ ក្នុងនោះរាប់បញ្ចូលទាំងការផ្តល់បរិយាកាសល្អផ្នែករូបវន្ត និងស្មារតីដល់កុមារា និង កុមារី ព្រមទាំងការបង្កើនឱកាសឲ្យប្រជាជនទទួលបាននូវការបណ្តុះបណ្តាលក្រៅប្រព័ន្ធ និងវិជ្ជាជីវៈសម្រាប់ស្ត្រី និងកុមារីផងដែរ។

### ២.១.២ ការផ្តល់អាហារូបករណ៍[32]

ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការស្បៀងអាហារពិភពលោក ចាប់ពីឆ្នាំ ២០១១-១២ មក បានបង្កើតកម្មវិធីអាហារូបករណ៍ជាសាច់ប្រាក់ជូនសិស្សានុសិស្សនៅតាមសាលាបឋមសិក្សា ចាប់ពីថ្នាក់ទី ៤ដល់ទី ៦ ពិសេសកុមារី កុមារមកពីក្រុមគ្រួសារក្រីក្រ នៅតាមតំបន់ដែលសិស្សអវត្តមានច្រើន លទ្ធផលសិក្សាមិនសូវល្អ ដោយសារពួកគេត្រូវទៅជួយឪពុកម្តាយរកប្រាក់ដោះស្រាយជីវភាពប្រចាំថ្ងៃ។

ដើម្បីជាកិច្ចតបស្នងចំពោះអង្គការស្បៀងអាហារពិភពលោក ថ្នាក់ដឹងនាំក្រសួងអប់រំ យុវ-ជន និងកីឡា និងអ្នកពាក់ព័ន្ធបានចុះពិនិត្យ និងសំណេះសំណាលជាមួយក្រុមកុមារដែលបានទទួលអាហារូបករណ៍ជាសាច់ប្រាក់តាមសាលាបឋមសិក្សានានាក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កម្មវិធីនេះបានផ្តល់ជាសាច់ប្រាក់សុទ្ធ ៥០ដុល្លាសហរដ្ឋអាមេរិក សម្រាប់សិស្សម្នាក់ ហើយត្រូវបើក ជូនជាបីដំណាក់កាល ក្នុងមួយឆ្នាំសិក្សា តាមរយៈប្រព័ន្ធធនាគារដែលនៅក្បែរមូលដ្ឋានពួកគេ។

[31] Minstry of Women's Affairs(MoWA)(2008) A Fair Share for Women: Cambodia Gendeer Assessment 2008, Executive Summary, Phnom Penh

[32] គណៈកម្មាធិការជាតិ អប់រំសម្រាប់ទាំងអស់គ្នា របាយការណ៍ ស្តីពី ការពិនិត្យឡើងវិញការអប់រំសម្រាប់ទាំងអស់គ្នា ថ្នាក់ជាតិ ឆ្នាំ២០១៥ ទំព័រ៥៦ ចំណុច៣.៣

ពីឆ្នាំសិក្សា ២០១១-១២ រហូតបច្ចុប្បន្ន កុមារដែលទទួលបានអាហារូបករណ៍ទាំងនោះ បានមករៀនទៀងទាត់ និងរៀនបានពូកែជាងសិស្សដទៃ។ សហគមន៍ លោកគ្រូ អ្នកគ្រូ និងមាតា បិតាកុមារទាំងនោះពេញចិត្តនឹងកម្មវិធីនេះណាស់ ពីព្រោះបានជួយសម្រាលបន្ទុកចំណាយរបស់គ្រួសារ ពិសេសគ្រួសារក្រីក្រ ហើយបានធ្វើឲ្យកុមារមករៀនទៀងទាត់ និងបានរៀនពូកែទៀត។

ក្រោយពីការព្យាយាមរបស់ក្រុមយើងខ្ញុំ ក្នុងការស្វែងរកទិន្នន័យជាក់លាក់ មកបញ្ជាក់អំពីចំនួនអាហារូបករណ៍ដែលរាជរដ្ឋាភិបាលបានផ្តល់ជូនទៅដល់ប្រជាពលរដ្ឋ ដែលស្ថិតនៅក្នុងកម្រិតសិក្សានីមួយៗ យើងពិតជាមានការពិបាកយ៉ាងខ្លាំង ដោយយើងពុំអាចរកចំនួនជាក់លាក់ដែលរាជរដ្ឋាភិបាល បានផ្តល់ដល់ប្រជាពលរដ្ឋចាប់ពីថ្នាក់មត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សាឡើយ។ យើងអាចរកបានត្រឹមតែអាហារូបករណ៍ ដែលធនាគារពិភពលោកបានផ្តល់មកតាមរយៈរដ្ឋាភិបាលមក ដល់កុមារី និងកុមារដូចដែលបានរៀបរាប់ខាងលើរួចមកហើយតែប៉ុណ្ណោះ។

## ២.២ ឧបសគ្គនាពេលបច្ចុប្បន្ន

ជាទូទៅស្ទើរតែគ្រប់វិស័យ វាតែងតែមានការជួបនៅបញ្ហាប្រឈមណាមួយ ដែលបណ្តាលឲ្យមានផលប៉ះពាល់ទៅនឹងដំណើរការនៃការធ្វើការទៅលើវិស័យនោះជាក់ជាមិនខានឡើយ។ ក្នុងនោះផងដែរ ក៏មានកត្តាមួយ ចំនួនជាបញ្ហាដែលកំពុងជួបប្រទះនៅក្នុងដំណើរការនៃវិស័យអប់រំ។ បញ្ហាទាំងនោះមានដូចជា៖**កត្តាក្រៅប្រព័ន្ធអប់រំ បញ្ហានៅកម្រិតសាលា និងបញ្ហាទាក់ទងនឹងគោល-នយោបាយតាមវិស័យ និងសមត្ថភាពស្ថាប័ន។**

### ២.២.១ កត្តាក្រៅប្រព័ន្ធអប់រំ[33]

ក្នុងនោះយើងបានជួបនឹងបញ្ហាដូចជា៖ **បញ្ហាប្រឈមផ្នែកសង្គម វប្បធម៌ និងសេដ្ឋកិច្ច។** យើងនឹងធ្វើការរៀបរាប់ជាចំណុចៗទាក់ទងនឹងបញ្ហាប្រឈមខាងលើនេះ។

- ផ្នត់គំនិតសង្គមលើទំនាក់ទំនងយេនឌ័រ នៅតែជាបញ្ហាប្រឈមដ៏ចម្បងក្នុងការបង្កើនឱកាសដល់ស្ត្រី និងក្មេងស្រី ដើម្បីទទួលបាននូវការអប់រំ និងការបណ្តុះបណ្តាលនានា។
- បញ្ហាសំខាន់ដែលនៅតែបន្តកើតមាន និងជាឧបសគ្គរាំងស្ទះដល់ការសិក្សារបស់កុមារ ជាពិសេសក្មេងស្រី ច្រើនកើតមាននៅក្នុងគ្រួសារដែលឪពុកម្តាយជាអនក្ខរជន ឬជាអ្នកដែលទទួលបានការអប់រំទាប ដែលភាគច្រើនកើតមាននៅតាមតំបន់ដាច់ស្រយាល។

[33] Minstry of Women's Affairs(MoWA)(2008) A Fair Share for Women: Cambodia Gendeer Assessment 2008, Executive Summary, Phnom Penh

- ទោះបីជាច្បាប់ បានកំណត់អាយុស្របច្បាប់ (១៨ឆ្នាំ) សម្រាប់អាពាហ៍ពិពាហ៍ក៏ពិតមែន ប៉ុន្តែការរៀបអាពាហ៍ពិពាហ៍មិនទាន់គ្រប់អាយុ នៅតែបន្តកើតមាននៅក្នុងសង្គមកម្ពុជា
- អំពើហិង្សាក្នុងគ្រួសារ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ដំណើរការបន្តការសិក្សារបស់កូនចៅ ជាពិសេសក្មេងស្រី។
- ការបោះការសិក្សាដើម្បីស្វែងរកប្រាក់ចំណូលសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ នៅតែជាអាទិភាពមួយដ៏ខ្ពស់សម្រាប់គ្រួសារក្រីក្រ។
- បរិស្ថានការងារនៅតាមរោងចក្រ សហគ្រាស នៅមិនទាន់បង្កឱកាសឲ្យកម្មករមានលទ្ធ ភាពបញ្ចប់ភូមិសិក្សាចំណេះទូទៅនៅឡើយ។

### ២.២.២ បញ្ហានៅកម្រិតសាលា

នេះគឺជាបញ្ហាមួយផ្សេងទៀតដែលយើងកំពុងជួបប្រទះដូចគ្នា ដែលបញ្ហាទាំងនោះមានៈ

- កិច្ចគាំពារលើកុមារនៅក្នុងសាលារៀននៅមានកម្រិត។
- គុណភាពនៃការបង្រៀន និងការរៀននៅមានកម្រិតនៅឡើយ ទាំងនៅក្នុងកម្មវិធីសិក្សា សៀវភៅសិក្សា និងគ្រូបង្រៀន។
- សមត្ថភាពថ្លឹងថ្លែងតម្លៃនៃការសិក្សា និងឱកាសរកប្រាក់ចំណូលនៅសម្រាប់គ្រួសាររបស់មាតាបិតា និងអាណាព្យាបាលសិស្សនៅមានកម្រិតទាបនៅឡើយ។
- លទ្ធភាពនៃកម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សមិនទាន់គ្របដណ្តប់ទូលំទូលាយ និងនៅពឹងអាស្រ័យជំនួយពីដៃគូរអភិវឌ្ឍវិស័យ។
- កាលវិភាគរបស់សាលាពុំទាន់ឆ្លើយតបពេញលេញទៅតាមតម្រូវការ និងរដូវកាលនៃការធ្វើស្រែចម្ការរបស់ប្រជាជននៅតាមមូលដ្ឋាននៅឡើយ។
- ការចូលរួមរបស់សហគមន៍ និងមាតាបិតាសិស្ស ក្នុងសកម្មភាពរបស់សាលា ក៏ដូចជាការសិក្សារបស់សិស្សនៅមានកម្រិត។

### ២.២.៣ បញ្ហាទាក់ទងនឹងគោលនយោបាយតាមវិស័យ និងសមត្ថភាពស្ថាប័ន

នេះជាបញ្ហាមួយចុងក្រោយ ដែលក្រុមរបស់យើងខ្ញុំនឹងធ្វើការដាក់បង្ហាញទាក់ទងទៅនឹងឧបសគ្គនាពេលបច្ចុប្បន្នដែលបណ្តាលឲ្យស្ត្រីមួយចំនួនមិនអាចមានឱកាសក្នុងការបន្តការសិក្សា។

- ក្រសួងបានកំណត់គោលនយោបាយ និងរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័របានល្អគួរជាទីមោទនៈ ប៉ុន្តែការអនុវត្តជាក់ស្តែងនៅមានកម្រិត។

- ការអភិវឌ្ឍន៍ធនធានស្ថាប័ន និងធនធានមនុស្សសម្រាប់សម្រេចបានគោលដៅបញ្ញាប យេនឌ័រនៅថ្នាក់ក្រោមជាតិនៅមានកម្រិត ព្រមទាំងមានការប្រឈមច្រើន។
- សេវាអប់រំមូលដ្ឋាន ត្រូវបានផ្តល់ដោយឥតគិតថ្លៃ ប៉ុន្តែការចំណាយក្រៅផ្លូវការផ្សេងៗ សម្រាប់ការសិក្សារបស់កុមារនៅតែជាកង្វល់មួយរបស់មាតាបិតា។

# សេចក្តីសន្និដ្ឋាន

យើងបានដឹងថា មានច្បាប់មួយចំនួនដែលមានទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ បានធ្វើការចែង ក្នុងគោលបំណងពង្រឹងយ៉ាងយកចិត្តទុកដាក់ទៅលើវិស័យអប់រំ ជាពិសេសគឺសិទ្ធិស្ត្រីក្នុងវិស័យអប់រំនេះតែម្តង។ ដូចដែលក្រុមរបស់យើងខ្ញុំបានរៀបរាប់តាំងពីដើមរួចមកហើយ ទាក់ទងទៅនឹងការខិតខំប្រឹងប្រែង ស្វះស្វែងរកជំនួយរបស់រាជរដ្ឋាភិបាល ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលពីគ្រប់មជ្ឈដ្ឋាន មិនថាតែនៅក្នុងប្រទេស និងក្រៅប្រទេសក្តី ក្នុងគោលបំណងយកសម្ភារៈ ក៏ដូចជាថវិកា នឹងដែលយើងអាចហៅសាមញ្ញម៉្យាងទៀតថាជាអាហារូបករណ៍នោះ ក្នុងការមកផ្តត់ផ្គង់ដល់សិស្ស និស្សិតឲ្យបានចូលរៀនកាន់តែច្រើនឡើង។ ដែលអាហារូបករណ៍ទាំងនោះ ភាគច្រើនគឺបានផ្តល់ទៅឲ្យសិស្ស និស្សិតក្រីក្រ ជាពិសេសគឺស្ត្រីតែម្តង។

បើទោះបីជាមានការជួយជ្រោមជ្រែងយ៉ាងសម្បើមពីសំណាក់រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលក៏ដោយ ក៏ការចូលរៀនរបស់ក្មេងស្រី និងស្ត្រីនៅមានកម្រិតទាបជាងក្មេងប្រុសនិងបុរសនៅឡើយ។ នោះដោយសារតែ ប្រជាជនមួយចំនួននៅតែប្រកាន់ខ្ជាប់នៅផ្នត់គំនិតថា ស្ត្រីបង្វិលចង្ក្រានមិនជុំ ហើយដែលក្រោយពីរៀបអាពាហ៍ពិពាហ៍ទៅ ស្ត្រីនឹងនៅតែផ្ទះដាំស្ល មើលថែកូនចៅ ផ្ទះសម្បែង ដែលបុរសជាប្តីគឺជាអ្នកទៅរកស៊ីចិញ្ចឹមដើម្បីជួយផ្គត់ផ្គង់ដល់ជីវភាពគ្រួសារ។ តែផ្នត់គំនិតនេះ ភាគច្រើន គឺនៅសេសសល់តែតំបន់ដែលពុំសូវមានប្រព័ន្ធទូរគមនាគមន៍អាចធ្វើការផ្សព្វផ្សាយទាក់ទងនឹងសមភាពយេនឌ័រទៅដល់តែប៉ុណ្ណោះ។ ភាគច្រើននៃប្រជាជនមួយចំនួនធំដែលបានទទួលព័ត៌មានតាមរយៈបណ្តាញសង្គមផ្សេងៗ គឺពួកគាត់បានធ្វើការកែប្រែនូវទស្សនៈវិស័យបែបនេះចោលស្ទើរតែទាំងអស់ហើយ។ តែអ្វីដែលជាបញ្ហានោះ គឺមកពីជីវភាពរស់នៅរកព្រឹកខ្វះល្ងាចរបស់ពួកគាត់ទេ ដែលជាហេតុធ្វើឲ្យពួកគាត់មិនអាចធ្វើការបញ្ជូនកូនៗរបស់ពួកគាត់ឲ្យទៅសាលាបាន ជាពិសេស បើសិនជាគាត់អាចមានលទ្ធភាពសម្រាប់តែកូនម្នាក់ឲ្យទៅរៀននោះ គាត់ប្រាកដជាផ្តល់អត្តិភាពឲ្យទៅកូនប្រុសមិនខានឡើយ ដោយគាត់នឹងទុកកូនស្រីឲ្យនៅជួយធ្វើកិច្ចការងារផ្ទះ ព្រោះជាធម្មតា នេះគឺជាកិច្ចការងារផ្ទះភាគច្រើនគឺស្ត្រីគឺជាអ្នកធ្វើស្រាប់ទៅហើយនៅក្នុងសង្គមខ្មែរតាំងពីដូនតាមក។

ដោយឡែក ប្រសិនណាជារាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងខ្នះខ្នែងក្នុងការរកជំនួយឧបត្ថម្ភទៅលើវិស័យនេះហើយក៏ដោយក្នុងនោះប្រជាពលរដ្ឋ ដែលជាម្តាយឪពុកគួរណាជួយជម្រុញ

កូនៗរបស់ខ្លួនឲ្យបានទៅរៀន នឹងព្យាយាមលើកទឹកចិត្ត ក៏ដូចជាពន្យល់ណែនាំកូនៗរបស់ ខ្លួនពីអត្ថប្រយោជន៍នៃការសិក្សា និងពីតម្លៃបន្ទាប់ពីបញ្ចប់ការសិក្សាដោយជោគជ័យ។

ការជួយជម្រុញរបស់មាតាបិតា និងអាណាព្យាបាល ការព្យាយាមរបស់បុគ្គលខ្លួនឯង និងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល ក្នុងការស្វែងរក ជំនួយពិតជាអាចជួយស្ត្រីឲ្យមានសក្តានុភាពដូចជាបុរសដែរ។

# អនុសាសន៍

នៅក្នុងនោះផងដែរ រាជរដ្ឋាភិបាលគួរណាចាត់នូវវិធានការមួយចំនួនទៀតដើម្បីជួយបន្ថែមនូវល្បឿនក្នុងការអភិវឌ្ឍន៍ចិត្តគំនិតរបស់ប្រជាពលរដ្ឋ ជាពិសេសបុរសឲ្យបែរមកមើលពីការឲ្យតម្លៃ ទៅលើស្ត្រីនៅក្នុងការសម្រេចចិត្ត ក៏ដូចជាសិទ្ធិផ្សេងៗទៀតអ្វីដែលសំខាន់នោះគឺការផ្តល់ឱកាស ឲ្យស្ត្រីបានចូលរៀន និងកាន់នូវមុខងារធំៗដូចជាបុរសដែរ។

ក្រសួងកិច្ចការនារី គប្បីអប់រំសាធារណៈជនអំពីការចូលរួមរបស់យេនឌ័រ និងការទទួលខុសត្រូវនៅក្នុងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសេដ្ឋកិច្ចគ្រួសារ និងមុខងារសំខាន់នៃមត្តេយ្យក្នុង និងក្រៅប្រព័ន្ធ។ ការយល់ដឹងរបស់សាធារណៈជនអំពីការចូលរួមរបស់យេនឌ័រ និងការទទួលខុសត្រូវក្នុងការកែប្រែទម្លាប់មិនល្អរបស់សង្គមអំពីការទទួលខុសត្រូវរបស់បុរស និងស្ត្រីក្នុងសង្គម ដែលថាមានតែបុរសតែប៉ុណ្ណោះ ដែលជាអ្នកទទួលខុសត្រូវចម្បងក្នុងការចិញ្ចឹមគ្រួសារ ហើយស្ត្រីត្រូវបានតម្រូវឲ្យធ្វើកិច្ចការផ្ទះ និងថែទាំកូនចៅ។ ពង្រឹងការតាមដាន និងត្រួតពិនិត្យចំពោះការចូលរៀនរបស់ក្មេងស្រី និងស្ត្រី ដើម្បីធ្វើយ៉ាងណាឲ្យពួកគេអនុវត្តតាមស្តង់ដារនៃកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។ នាយកដ្ឋានអប់រំនៃក្រសួងកិច្ចការនារី អាចកែសម្រួលគោលនយោបាយរបស់ខ្លួនអំពីការអប់រំស្ត្រី ដើម្បីសម្របសម្រួលគំនិតផ្តួចផ្តើមឲ្យបានល្អប្រសើរជាមួយដៃគូរបស់ខ្លួនដោយរួមបញ្ចូលមុខងារសកម្មភាពគំរូ និងសាកល្បងអនុវត្តឲ្យបានល្អប្រសើរ នូវកម្មវិធីសកម្មភាពអាទិភាពរបស់ខ្លួន។ រៀបចំយុទ្ធសាស្ត្រច្បាស់លាស់តាមវិស័យ និងផែនការសកម្មភាព ដើម្បីទាក់ទាញការផ្តល់មូលនិធិពីម្ចាស់ជំនួយ និងការសន្យារបស់ម្ចាស់ជំនួយជាជាងទុកឲ្យម្ចាស់ជំនួយដឹកនាំវិស័យនេះ។ យុទ្ធសាស្ត្រតាមវិស័យ គប្បីបញ្ជាក់មុខងារ និងការទទួលខុសត្រូវរបស់ស្ថាប័នរាជរដ្ឋាភិបាលផ្សេងៗ និងផែនការស្នើសុំឲ្យមានមណ្ឌលថែទាំកុមារី និងសាលាជំនាញក៏ដូចជាសាលារៀន នៅទូទាំងប្រទេស និងយន្តការដើម្បីជម្រុញការសម្របសម្រួល និងសហប្រតិបត្តិការល្អប្រសើរក្នុង ចំណោមភាគីពាក់ព័ន្ធនានា។ ជាមួយគ្នានេះដែរផែនការនេះ ក៏គប្បីបញ្ជាក់ឲ្យបានច្បាស់អំពីវិធីគ្រប់ គ្រងគ្រូបង្រៀន ដែលបញ្ចប់ការសិក្សារៀងរាល់រយៈពេល២ឆ្នាំម្តង ឲ្យឆ្លងតបទៅនឹងតម្រូវការពង្រីក ក្នុងការអនុវត្តន៍គោលដៅរបស់ខ្លួននៅឆ្នាំ២០១០ និង ២០១៥ និងដើម្បីកំណត់រកយុទ្ធសាស្ត្រនានា ក្នុងគោលបំណងទាញផលជាអតិបរិមាឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល គួរណាចាប់ផ្តើមជម្រុញ និងកសាងគំរូនៃជោគជ័យនានាក្នុងពេលបច្ចុប្បន្នដូចជា៖

- អនុវត្តច្បាប់ការងារឲ្យដាក់បញ្ចូលមណ្ឌលថែទាំកុមារី និងកន្លែងស្នាក់សម្រាប់ក្មេងស្រី និងស្ត្រីបន្ថែមទៀត ដើម្បីឲ្យពួកគេបានបន្តការសិក្សានៅទីក្រុង។
- ជម្រុញឲ្យអង្គការមិនមែនរដ្ឋាភិបាលគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការថែទាំ និងអភិវឌ្ឍយេនឌ័រនៅក្នុងវិស័យអប់រំ។
- ផ្តល់នូវយានជំនិះ ដូចជាកង់សម្រាប់ឲ្យក្មេងស្រី និងស្ត្រីមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅសាលារៀនបាន
- ផ្តល់ជូននូវប័ណ្ណពិនិត្យសុខភាពដោយឥតគិតថ្លៃចំពោះជម្ងឺទូទៅ នឹងធ្វើការបញ្ចុះតម្លៃចំពោះជម្ងឺមួយចំនួនដែលមានការចំណាយខ្ពស់។
- ផ្តល់ជាកញ្ចប់ថវិកាសម្រាប់ការចំណាយប្រចាំឆ្នាំចំពោះសិស្ស និស្សិតដែលមានជីវភាពលំបាកខ្លាំង។

ចំពោះប្រជាពលរដ្ឋខ្លួនឯងវិញ បើទោះបីជាមានការជួយជ្រោមជ្រែងយ៉ាងណាអំពីសំណាក់រាជរដ្ឋាភិបាល និងបណ្តាលអង្គការមិនមែនរដ្ឋាភិបាលក្តី ក៏វានៅតែទាន់គ្រប់គ្រាន់នៅឡើយក្នុងការជួយជម្រុញឲ្យប្រទេសកម្ពុជាមានល្បឿនលឿនក្នុងការអភិវឌ្ឍន៍ខ្លួន ឲ្យក្លាយទៅជាមានសក្តានុភាពផ្នែកអប់រំដែរ។ បើសិនជាក្នុងនោះ ប្រជាពលរដ្ឋខ្លួនឯងមិនបានខិតខំប្រឹងប្រែងខ្នះខ្នែងខំប្រឹងរៀនសូត្របន្ថែមដោយខ្លួនឯងទេនោះ ក៏ជំនួយដែលបានមកមិនមានឥទ្ធិពលក្នុងការជួយស្តារនូវជីវភាពសង្គម និងគ្រួសារដែរ។

ការចូលរួមទាំងអស់គ្នា គឺជាដំណោះស្រាយដ៏ប្រសើរ ដែលអាចនាំប្រទេសជាតិទាំងមូលឈានឆ្ពោះទៅកាន់ភាពរីកចម្រើន និងអាចចូលខ្លួនក្នុងទីផ្សារសេរីបានយ៉ាងមានមោទនៈភាព។

ការជួយលើកតម្លៃស្ត្រីឲ្យទទួលបានការសិក្សាខ្ពស់ គឺជាការជួយលើកតម្លៃខ្លួនឯង និងជាក៏ការលើកកម្ពស់ប្រទេសរបស់ខ្លួនឲ្យបានឈរនូវលំដាប់មួយ ដែលបណ្តាលប្រទេសដ៏ទៃស្ញើចសរសើរ និងការគោរព។

## ឯកសារយោង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ការអនុវត្តន៍ផែនការគោលប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ២០១៤-២០១៨
- ក្រសួងអប់រំ យុវជន និងកីឡា **ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩-២០១៣** (ថ្ងៃទី ២០ខែកញ្ញាឆ្នាំ២០១០)
- ក្រសួងអប់រំ យុវជន និងកីឡា **ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨** (ថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១៤)
- គណៈកម្មាធិការជាតិអប់រំសម្រាប់ទាំងអស់គ្នា របាយការណ៍ស្តីពី ការពិនិត្យឡើងវិញ ការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ជាតិឆ្នាំ ២០១៥
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជនកម្ពុជា
- **«យុទ្ធសាស្ត្រចតុកោណ»***ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពនៅកម្ពុជា* ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា(រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ ២០១៣)
- សន្ទរកថា របស់សម្តេច ហ៊ុនសែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពី **«យុទ្ធសាស្ត្រចតុកោណ»***ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពនៅកម្ពុជា*ថ្លែង នៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ នីតិកាលទី៣ នៃរដ្ឋសភា នៅទីស្តីការគណៈ រដ្ឋមន្ត្រី (រាជធានីភ្នំពេញថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០០៤)
- សន្ទរកថារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រី នៃព្រះរាជា-ណាចក្រកម្ពុជា ស្តីពី **«យុទ្ធសាស្ត្រចតុកោណ»** *ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពនៅកម្ពុជា* ដំណាក់កាលទី២ ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា (រាជធានីភ្នំពេញថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៨)
- ស្ថិតិ និងសូចនាករអប់រំឆ្នាំ២០១១-២០១២
- ស្ថិតិ និងសូចនាករអប់រំឆ្នាំ២០១២-២០១៣
- Ministry of Women′s Affairs (MoWA)(2008) A Fair Share for Women:Cambodia Gender Assessment 2008. Executive Summary, Phnom Penh.
- Edward B.Fiske,September,1995ការប្រើប្រាស់ដៃទាំងគូ ស្ត្រីក្នុងវិស័យអប់រំនៅកម្ពុជា

# សេចក្ដីផ្ដើម

# ឧបសម្ព័ន្ធ